# កិច្ចព្រមព្រៀង នៅទីក្រុងប៉ារីស អំពីបញ្ហាកម្ពុជា

២៣ តុលា ១៩៩១

# កិច្ចព្រមព្រៀង ស្ដីពីដំណោះស្រាយ នយោបាយរួមមួយ នៃជម្លោះកម្ពុជា


I. កិច្ចព្រមព្រៀង ស្ដីពីដំណោះស្រាយ នយោបាយរួមមួយ នៃជំលោះកម្ពុជា

ឧបសម្ព័ន្ធ

១. ភារកិច្ចរបស់អាជ្ញាធរបណ្ដោះអាសន្ន នៃអង្គការសហប្រជាជាតិ នៅកម្ពុជា "អ៊ុនតាក់"

ក. នីតិក្រមរួម

ខ. រដ្ឋាភិបាលស៊ីវិល

គ. មុខងារខាងយោធា

ឃ. កាបោះឆ្នោត

ង. សិទ្ធិមនុស្ស

២. ការដកទ័ព ការឈប់បាញ់ និង វិធានការពាក់ព័ន្ធ

៣. ការបោះឆ្នោត

៤. មាតុភូមិនិវត្តន៍ នៃជនភៀសខ្លួនកម្ពុជា និង ជនផ្លាស់ប្ដូរទីកន្លែងកម្ពុជា

៥. គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

II. កិច្ចព្រមព្រៀងស្ដីពី អធិបតេយ្យភាព បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដីអព្យាក្រិតភាព និង ឯក ភាពជាតិរបស់កម្ពុជា

III. សេចក្ដីថ្លែងការណ៍ ស្ដីពីការស្តារ និង កសាងប្រទេសកម្ពុជាឡើងវិញ

IV. កិច្ចព្រមព្រៀងចុងក្រោយ នៃសន្និសិទប៉ារីសពីកម្ពុជា

## I. កិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយ នយោបាយរួមមួយ នៃជំលោះកម្ពុជា

បណ្តារដ្ឋ ដែលបានចូលរួមក្នុងសន្និសិទទីក្រុងប៉ារិស ស្តីពីកម្ពុជា គឺ អូស្ត្រាលី ប្រ៊ុយណេ ដារូស្សាឡាម កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋបារាំង សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន សាធារណរដ្ឋប្រជាធិប- តេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបូរី រាជាណាចក្រថៃឡង់ សហភាពសាធារណរដ្ឋ សង្គមនិយមសូវៀត ចក្រភពអង់គ្លេស និង អៀរឡង់ខាងជើង សហរដ្ឋអាមេរិក សាធារណរដ្ឋសង្គមនិយមវៀតណាម និង សាធារណរដ្ឋ សហព័ន្ធសង្គមនិយមយូហ្គោស្លាវី ។

នៅចំពោះវត្តមាន នៃលោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ ។

ដើម្បីថែរក្សា និង ការពារអធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដីអព្យាក្រិតភាព និងឯកភាពជាតិរបស់កម្ពុជា ។

*ដោយចង់ស្តារ* ឡើងវិញ និង ថែរក្សាសន្តិភាពនៅកម្ពុជា ជំរុញឱ្យមានការរួបរួមជាតិ និង ធានាឱ្យប្រជាជនកម្ពុជាប្រើប្រាសសិទ្ធិស្វ័យសម្រេច តាមរយៈការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ។

*ដោយជឿជាក់ថា* មានតែដំណោះស្រាយ នយោបាយរួមមួយ សម្រាប់ជំលោះកម្ពុជាទេ ទើបបានដំណោះស្រាយមួយយុត្តិធម៌ និង យូរអង្វែង ហើយនឹងរួមវិភាគទានដល់សន្តិភាព និង សន្តិសុខក្នុងតំបន់ និង អន្តរជាតិ ។

*ដោយស្វាគមន៍* ឯកសារក្របខ័ណ្ឌ ថ្ងៃទី ២៨ សីហា ១៩៩០ ដែលបានព្រមព្រៀងទាំងស្រុង ដោយភាគីកម្ពុជាធ្វើជាមូលដ្ឋាន សម្រាប់ដំណោះស្រាយ នៃជំលោះកម្ពុជា ហើយបន្ទាប់មក ត្រូវបានយល់ព្រមព្រៀងជាឯកច្ឆ័ន្ទ ដោយក្រុមប្រឹក្សាសន្តិសុខ តាមសេចក្តីសម្រេចចិត្តលេខ ៦៦៨ "១៩៩០" ចុះថ្ងៃទី ២០ កញ្ញា ១៩៩០ និង ដោយមហាសន្និបាត អ.ស.ប. តាមសេចក្តី សម្រេចចិត្តលេខ ៤៥.៣ ចុះថ្ងៃទី ១៥ តុលា ១៩៩០ ។

*ដោយកត់សម្គាល់* ការបង្កើតឡើង នូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៃកម្ពុជានៅហ្សាកាតា ថ្ងៃទី ១០ កញ្ញា ១៩៩០ ជាអង្គការ ស្ថាប័នស្របច្បាប់ និង ជាប្រភពអំណាចតែមួយគត់នៅកម្ពុជា ដែលនៅក្នុងទូទាំងដំណាក់កាលអន្តរកាល ជាតំណាងតំកល់ អធិបតេយ្យភាព និង ឯកភាពជាតិ ហើយដែលតំណាងកម្ពុជានៅបរទេស ។

*ដោយស្វាគមន៍* ការជ្រើសតាំងជាឯកច្ឆ័ន្ទ នូវសម្តេច នរោត្តម សីហនុ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅប៉េកាំង ថ្ងៃទី ១៧ កញ្ញា ១៩៩១ ។

*ដោយទទួលស្គាល់ថា* តួនាទីដ៏ទូលំទូលាយ របស់អង្គការសហប្រជាជាតិ ទាមទារឱ្យបង្កើតអាជ្ញាធរបណ្តោះអាសន្ន របស់អង្គការសហប្រជាជាតិមួយនៅកម្ពុជា "អ៊ុនតាក់" ដោយមានផ្នែកយោធា និង ផ្នែកស៊ីវិល ដែលនឹងបំពេញភារកិច្ច ដោយគោរពទាំង ។

ស្រុងដល់អធិបតេយ្យភាពរបស់កម្ពុជា ។

*ដោយកត់សម្គាល់* នូវសេចក្ដីថ្លែងការណ៍ នៅពេលចប់កិច្ចប្រជុំ ដែលបានប្រព្រឹត្តទៅនៅហ្សាកាតា ថ្ងៃទី ៩ - ១០ កញ្ញា ១៩៩០ នៅប៉ារីស ថ្ងៃទី ២១ - ២៣ ធ្នូ ១៩៩០ នៅប៉ាតាយ៉ា ថ្ងៃទី ២៤ - ២៦ មិថុនា ១៩៩១ នៅប៉េកាំង ថ្ងៃទី ១៦ - ១៧ កក្កដា ១៩៩១ នៅប៉ាតាយ៉ាថ្ងៃទី ២៦ - ២៩ សីហា ១៩៩១ ព្រមទាំងកិច្ចប្រជុំនៅហ្សាកាតា ថ្ងៃទី ៤ - ៦ មិថុនា ១៩៩១ និង នៅញូវយ៉ក ថ្ងៃទី ១៩ កញ្ញា ១៩៩១ ។

*ដោយស្វាគមន៍* សេចក្ដីសម្រេចចិត្តរបស់ ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិលេខ ៧១៧ "១៩៩១" ចុះថ្ងៃទី ១៦ តុលា ១៩៩១ ស្ដីពីកម្ពុជា ។

*ដោយទទួលស្គាល់ថា* ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មរបស់កម្ពុជា ទាមទារឱ្យមានវិធានការណ៍ពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស និង ការមិនវិលត្រឡប់មកវិញ នៃនយោបាយ និង អំពើប្រព្រឹត្តពីអតីតកាល ។

*ដែលបានព្រមព្រៀង* ដូចតទៅនេះ

# **ភាគទី ១**

# ការរៀបចំក្នុងដំណាក់កាល អន្តរកាល

## *ផ្នែកទី ១*

## ដំណាក់កាលអន្តរកាល

### **មាត្រាទី ១**

ដើម្បីបំពេញវត្ថុបំណង នៃកិច្ចព្រមព្រៀងនេះ ដំណាក់អន្តរកាល ត្រូវចាប់ផ្ដើមពីពេលដែលកិច្ចព្រមព្រៀងនេះ ចូលជាធរមាន ហើយត្រូវបញ្ចប់នៅពេលដែលមានសភាធម្មនុញ្ញ ដែលបានជាប់ឆ្នោតតាមរយៈនៃការបោះឆ្នោត ដោយសេរី និង ត្រឹមត្រូវ ដែលរៀបចំឡើង និង បញ្ជាក់ដោយ អង្គការសហប្រជាជាតិ បានអនុមតិរដ្ឋធម្មនុញ្ញ ហើយបានក្លាយខ្លួនឯង ទៅជាសភានីតិបញ្ញត្តិ រួចបន្ទាប់មករដ្ឋាភិបាលថ្មីមួយ ត្រូវបានបង្កើតឡើង ។

*ផ្នែកទី ២*

## អាជ្ញាធរបណ្ដោះអាសន្ន នៃអង្គការសហប្រជាជាតិ នៅកម្ពុជា

## មាត្រាទី ២

១ - ហត្ថលេខីទាំងឡាយ ស្នើក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ឱ្យបង្កើតអាជ្ញាធរបណ្ដោះអាសន្ន នៃ អ.ស.ប. មួយនៅកម្ពុជា (ចាប់ពីពេលនេះតទៅ ហៅថាអ៊ុនតាក់ "UNTAC" ដោយរួមមានទាំងផ្នែកយោធា និងផ្នែកស៊ីវិល ដែលស្ថិតនៅក្រោមការទទួល ខុសត្រូវផ្ទាល់ របស់អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ។ ដើម្បីសម្រេចគោលបំណងនេះ លោកអគ្គលេខធិការ នៃ អ.ស.ប. ត្រូវចាត់តាំងតំណាងពិសេសម្នាក់ ឱ្យបំពេញភារកិច្ចក្នុងនាមរបស់លោក ។

២ - ហត្ថលេខីទាំងឡាយ ក៏ស្នើថែមទៀត ដល់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ឱ្យប្រគល់ដល់អ៊ុនតាក់ "UNTAC" នូវតួនាទីភារកិច្ចមួយ ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ហើយត្រូវពិនិត្យការអនុវត្តភារកិច្ចនេះ ឱ្យបានជារៀងរហូរហែ តាមរយៈរបាយការណ៍ទៀតទាត់ ធ្វើដោយលោកអគ្គលេខាធិការ ។

*ផ្នែកទី ៣*

## ក្រុមប្រឹក្សាជាតិជាន់ខ្ពស់

## មាត្រាទី ៣

ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (ចាប់ពីពេលនេះទៅ ហៅថា "អេសអិនស៊ី SNC" ) ជាអង្គការស្របច្បាប់ និង ជាប្រភពនៃអំណាចតែមួយគត់ ដែលតំណាងតំកល់អធិបតេយ្យភាព ឯករាជ្យ និង ឯកភាព នៃកម្ពុជាក្នុងដំណាកាល អន្តរកាល ។

## មាត្រាទី ៤

បណ្ដាសមាជិក អេសអិនស៊ី "SNC" នឹងត្រូវសន្យាឱ្យមានការចាត់តាំង ការពារដោយសេរី និង ត្រឹមត្រូវរៀបចំឡើង និងដឹកនាំដោយសហប្រជាជាតិ ធ្វើជាមូលដ្ឋានសម្រាប់រៀបចំរដ្ឋាភិបាលថ្មី និង ស្របច្បាប់មួយ ។

## មាត្រាទី ៥

នៅទូទាំងដំណាក់កាលអន្តរកាល អេសអិនស៊ី "SNC" ជាដំណាងកម្ពុជានៅក្រៅប្រទេស ហើយត្រូវកាន់កាប់អាសនៈកម្ពុជានៅឯ អ.ស.ប. នៅអង្គការជំនាញទាំងឡាយរបស់ អ.ស.ប. និង នៅក្នុងស្ថាប័នអន្តរជាតិ និង នៅក្នុងបណ្តាសន្និសិទអន្តរជាតិ ផ្សេងៗទៀត ។

## មាត្រាទី ៦

អាស្រ័យដោយហេតុនេះ អេសអិនស៊ី ប្រគល់អំណាចទាំងអស់ ដែលចាំបាច់ឱ្យអ៊ុនតាក់ ដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងនេះ ដូចមានពិពណ៌នា នៅក្នុងឧបសម្ព័ន្ធទី ១ ស្រាប់ ។

ដើម្បីធានាឱ្យមានបរិយាកាស នយោបាយអព្យាក្រិតមួយ សម្រួលដល់ការបោះឆ្នោតទូទៅ ដោយសេរី និង ត្រឹមត្រូវ គេត្រូវដាក់បណ្តាភ្នាក់ងារ ស្ថាប័ន និង ការិយាល័យ រដ្ឋបាលណា ដែលអាចជះឥទ្ធិពល ដោយផ្ទាល់ទៅលើលទ្ធផលនៃការបោះឆ្នោត ឱ្យស្ថិតនៅក្រោមការពិនិត្យមើល ឬ ត្រួតពិនិត្យដោយផ្ទាល់របស់អង្គការសហប្រជាជាតិ ។ ក្នុងក្របខ័ណ្ឌនេះ គេត្រូវចាប់អារម្មណ៍ ពិសេស ទៅលើកិច្ចការងារការបរទេស ការពារប្រទេស ហិរញ្ញវត្ថុ សន្តិសុខសាធារណៈ និង ឃោសនាការ ។ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញសារៈសំខាន់នៃបញ្ហានេះ អ៊ុនតាក់ "UNTAC" ចាំបាច់ត្រូវធ្វើការ ត្រួតពិនិត្យតាមដែលចាំបាច់ ដើម្បីធានាអព្យាក្រិតភាពម៉ឺងម៉ាត់ នៃបណ្តាស្ថាប័ន ដែលទទួខុសត្រូវ លើវិស័យទាំងនេះ ។ អង្គការសហប្រជាជាតិ ដោយមានការពិគ្រោះ ជាមួយអេសអិនស៊ី "SNC" ត្រូវពិនិត្យកំណត់មើលថា តើភ្នាក់ងារណា ស្ថាប័នណា និង ការិយាល័យណា ដំណើរការសកម្មភាពទៅទៀត ដើម្បីធានា ជីវភាពប្រចាំថ្ងៃធម្មតា នៅក្នុងប្រទេស ។

## មាត្រាទី ៧

ទំនាក់ទំនងរវាង អេសអិនស៊ី "SNC" និង អ៊ុនតាក់ "UNTAC" និង ជាមួយរចនាសម្ព័ន្ធរដ្ឋបាល ដែលមានស្រាប់ មានចែងនៅក្នុងឧបសម្ព័ន្ធ ទី ១ ។

*ផ្នែកទី ៤*

## ការដកកងកម្លាំងបរទេស និង ការពិនិត្យបញ្ជាក់

# មាត្រាទី ៨

ពេលកិច្ចព្រមព្រៀងនេះ ចូលជាធរមានភ្លាម រាល់កងកម្លាំងទីប្រឹក្សា និង បុគ្គលិកយោធា ទាំងឡាយណា ដែលមាននៅក្នុង ប្រទេសកម្ពុជា រួមទាំងសព្វាវុធ គ្រាប់រំសេវ និង សម្ភារៈរបស់គេ ត្រូវដកចេញពីកម្ពុជា និង មិនត្រូវត្រឡប់មកវិញទេ ។ ការដកកង កម្លាំង និងការមិនត្រឡប់នេះ នឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យ បញ្ជាក់របស់អ៊ុនតាក់ "UNTAC" ស្របតាមឧបសម្ព័ន្ធទី ២ ។

## *ផ្នែកទី ៥*

## ការឈប់បាញ់គ្នានិងការបញ្ឈប់នូវជំនួយយោធាពីខាងក្រៅ

# មាត្រាទី ៩

ការឈប់បាញ់គ្នា ត្រូវចាប់អនុវត្ត ចាប់តាំងពីពេលដែលកិច្ចព្រមព្រៀង ចូលជាធរមាន ។ គ្រប់កងកម្លាំងទាំងអស់ ត្រូវដោះដៃឈប់បាញ់គ្នាភ្លាម ហើយត្រូវផ្អាកឈប់ធ្វើសកម្មភាព ប្រទូស្តរាយគ្នាទាំងអស់ និង ឈប់ដាក់ពង្រាយទ័ព ចល័តទ័ព ឬធ្វើសកម្មភាពទាំងឡាយណា ដែលនាំឱ្យពង្រីកដែនដី ដែលខ្លួនត្រួតត្រា ឬក៏ដែលអាចនាំទៅ រកការប្រយុទ្ធគ្នាជាថ្មី ។

ហេតុនេះ បណ្តាហត្ថលេខី ស្នើដល់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ឱ្យស្នើទៅលោកអគ្គលេខាធិការ ឱ្យជួយឧបត្ថម្ភសម្រួលដល់ដំណើរការនេះ រហូតដល់ពេលដែលផ្នែកយោធារបស់ អ៊ុនតាក់ "UNTAC" អាចមានលទ្ធភាពពិនិត្យមើលតាមដាន និងបញ្ជាក់អំពីការឈប់បាញ់គ្នានេះ ។

# មាត្រាទី ១០

នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវបញ្ឈប់ជាបន្ទាន់នូវ ជំនួយយោធាបរទេសទាំងអស់ ទៅឱ្យភាគីកម្ពុជាទាំងអស់ ។

# មាត្រាទី ១១

ទិសដៅនៃការរៀបចំផ្នែកយោធា ក្នុងដំណាក់កាលអន្តរកាល គឺត្រូវធ្វើឱ្យ ស្ថានការណ៍សន្តិសុខមានស្ថិរភាព និងកសាងទំនុកចិត្តគ្នា រវាងបណ្តាភាគីក្នុងជំលោះ ដើម្បីពង្រឹងគោលបំណង នៃកិច្ចព្រមព្រៀងនេះ និង ដើម្បីទប់ស្កាត់គ្រោះថ្នាក់នៃការវិលត្រឡប់ទៅរកសង្គ្រាមវិញ ។

បទបញ្ញត្តិលំអិត ស្តីពីការត្រួតពិនិត្យ ការតាមដាន និង បញ្ជាក់អំពីការឈប់បាញ់គ្នា និង វិធានការពាក់ព័ន្ធ រួមទាំងការបញ្ជាក់ អំពីការដកទ័ពបរទេស និង ការប្រមូលផ្តុំការដាក់ក្នុងបន្ទាយ និង ការដោះស្រាយជាចុងក្រោយ នៃកងកម្លាំងកម្ពុជាទាំង អស់ ព្រមទាំងសព្វាវុធរបស់គេ នៅក្នុងដំណាក់កាលអន្តរកាល មានចែងនៅក្នុងឧបសម្ព័ន្ធទី ១ ជំពូក គ និងឧបម្ព័ន្ធទី ២ ។

# ភាគទី ២

## ការបោះឆ្នោត

## មាត្រាទី ១២

ប្រជាជនកម្ពុជាត្រូវមាន សិទ្ធិសម្រេចពីអានាគត នយោបាយរបស់ខ្លួន តាមរយៈការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ដើម្បីរើសសភាជម្មនុញ្ញមួយ ដែលត្រូវព្រាង និង អនុមតិរដ្ឋធម្មនុញ្ញកម្ពុជាមួយថ្មី ស្របទៅតាមមាត្រាទី ២៣ រួចត្រូវក្លាយខ្លួនទៅជា សភានីតិបញ្ញត្តិ ដែលត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាមួយថ្មី ។ការបោះឆ្នោតនេះ ធ្វើឡើងក្រោមការឧបត្ថម្ភដឹកនាំរបស់ អ.ស.ប. ក្នុងបរិយាកាសនយោបាយអព្យាក្រិតមួយ ដោយមានការគោរព ដោយពេញលេញដល់ អធិបតេយ្យភាពជាតិរបស់កម្ពុជា ។

## មាត្រាទី ១៣

អ៊ុនតាក់ "UNTAC" ត្រូវទទួលខុសត្រូវចំពោះការរៀបចំ និង ដឹកនាំការបោះឆ្នោតទាំងនេះ ដោយផ្អែកលើប្រការទាំងឡាយ ដែលអាចមានចែងក្នុងឧបសម្ព័ន្ធទី ១ ជំពូក ឃ និង ឧបសម្ព័ន្ធទី ៣ ។

## មាត្រាទី ១៤

ហត្ថលេខីទាំងអស់ ត្រូវប្តេជ្ញាគោរពលទ្ធផល នៃការបោះឆ្នោតទាំងនេះ នៅពេលណាដែលអង្គការ សហប្រជាជាតិបានបញ្ជាក់ថា ការបោះឆ្នោតនោះ បានប្រព្រឹត្តទៅដោយសេរី និង ត្រឹមត្រូវហើយ ។

# ភាគទី ៣

## សិទ្ធិមនុស្ស

# មាត្រាទី ១៥

១ - មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និង ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែង នៅកម្ពុជាទាំងអស់ ត្រូវមានសិទ្ធិ និង សេរីភាព ដែលមានចែងនៅក្នុង សេចក្តីប្រកាសជាសាកលពីសិទ្ធិមនុស្ស និង ក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយ ដែលពាក់ព័ន្ធដល់ស្តីពីសិទ្ធិមនុស្ស ។

២ - ដើម្បីសម្រេចទិសដៅនេះ

ក - ប្រទេសកម្ពុជាសន្យាថានឹងៈ

- ធានាគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស និង សេរីភាព ជាមូលដ្ឋាននៅកម្ពុជា ។
- គាំទ្រសិទ្ធិរបស់ពលរដ្ឋកម្ពុជាទាំងអស់ ក្នុងការធ្វើសកម្មភាព ដែលជំរុញ និង ការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ។
- ចាត់បណ្តាវិធានការ ដ៏មានប្រសិទ្ធិភាព ដើម្បីធានាថា នយោបាយ និង អំពើប្រព្រឹត្តក្នុងអតីតកាល មិនត្រូវបានអនុញ្ញាតិឱ្យវិលត្រឡប់មកវិញជាដាច់ខាត ។
- ចូលរួមកិច្ចព្រមព្រៀងជាអន្តរជាតិទាំងឡាយ ដែលពាក់ព័ន្ធដល់ សិទ្ធិមនុស្ស ។

ខ - ហត្ថលេខីផ្សេងៗ ទៀត នៃកិច្ចព្រមព្រៀងនេះសន្យាថាជួយជំរុញ និង លើកទឹកចិត្តដល់ការគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាននៅកម្ពុជា ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អន្តរជាតិទាំងឡាយ និង សេចក្តីសម្រេចទាំងឡាយរបស់មហាសន្និបាត អ.ស.ប. ដែលទាក់ទងនឹងបញ្ហានេះ ដើម្បីជាពិសេសការពារទប់ទល់នឹង ការកើតឡើងវិញ ការរំលោភសិទ្ធិមនុស្សជាថ្មីទៀត ។

# មាត្រាទី ១៦

ក្នុងដំណាក់កាលអន្តរកាល អ៊ុនតាក់ "UNTAC" ត្រូវទទួលខុសត្រូវ បណ្តុះបណ្តាលបរិយាកាសមួយ ធានាដល់ការគោរពសិទ្ធិមនុស្ស ដោយផ្អែកលើការ ដែលមានចែងក្នុងឧបសម្ព័ន្ធទី ១ ជំពូក ង ។

# មាត្រាទី ១៧

ក្រោយពីរយៈកាលអន្តរកាលត្រូវបានបញ្ចប់ គណៈកម្មការ អ.ស.ប. ស្តីពីសិទ្ធិមនុស្ស គប្បីបន្តតាមដានជិតដល់ពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា ហើយបើចាំបាច់មានរួមទាំងការតែងតាំង អ្នកធ្វើកំណត់ហេតុពិសេសម្នាក់ ដែលត្រូវធ្វើរបាយការណ៍ ប្រចាំឆ្នាំស្តីពីលទ្ធផលនៃ ការរកឃើញរបស់ខ្លួន ទៅជូនគណៈកម្មការ និង មហាសន្និបាត ។

# ភាគទី ៤

## ការធានាអន្តរជាតិ

## មាត្រាទី ១៨

កម្ពុជាសន្យាថា នឹងថែរក្សា ការពារ ហើយហត្ថលេខីឯទៀតៗ សន្យាថា ទទួលស្គាល់និងគោរព ចំពោះ អធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រិតភាព និង ឯកភាពជាតិនៃកម្ពុជា ដូចមានចែងក្នុងកិច្ចព្រមព្រៀងមួយដាច់ដោយឡែក ។

# ភាគទី ៥

## ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែង

## មាត្រាទី ១៩

ចាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន គេត្រូវខិតខំប្រឹងប្រែង ដើម្បីបង្កើតឱ្យមានលក្ខណសម្បត្តិ នយោបាយ សេដ្ឋកិច្ច និង សង្គមនៅក្នុងប្រទេសកម្ពុជា ដែលនាំសម្រួលឱ្យដល់ការវិលត្រឡប់ ដោយស្ម័គ្រចិត្តនិងការចូលមកក្នុងសង្គមជាតិវិញ ដោយសុខដុមរមនា នៃជនភៀសខ្លួននិង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ។

## មាត្រាទី ២០

១ - ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ដែលស្នាក់នៅក្រៅកម្ពុជា ត្រូវមានសិទ្ធិវិលត្រឡប់ មកប្រទេសកម្ពុជាវិញ និងរស់នៅដោយសុវត្ថិភាព សន្តិសុខ និងភាពថ្លៃថ្នូរ ដោយគ្មានការសំឡុតកំហែង ឬ ការគាបសង្កត់បែបណាមួយឡើយ ។

២ - ហត្ថលេខីទាំងឡាយ សូមស្នើចំពោះលោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ ឱ្យជួយជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ នៃជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ឱ្យប្រកបដោយសុវត្ថិភាព និងភាពថ្លៃថ្នូរ ក្នុងក្របខ័ណ្ឌជាភាគមួយ នៃដំណោះស្រាយនយោបាយរួម ដែលប្រព្រឹត្តទៅក្រោមអំណាចទូទៅ របស់តំណាងពិសេស នៃលោកអគ្គលេខាធិការ ស្របតាមសេចក្តីណែនាំ និង គោលការណ៍ស្តីពីមាតុភូមិនិវត្តន៍ នៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែង ដូចដែលមានចែងនៅក្នុង ឧបសម្ព័ន្ធទី ៤ ។

# ភាគទី ៦

## ការដោះលែងឈ្លើយសឹក និង ជនស៊ីវិលជាប់ឃុំ

### មាត្រាទី ២១

ការដោះលែងឈ្លើយសឹក និង ជនស៊ីវិលជាប់ឃុំឃាំងទាំងអស់ ត្រូវសម្រេចឡើងក្នុងពេល ដ៏ឆាប់រហ័យបំផុត តាមដែលអាចធ្វើទៅបាន ក្រោមការដឹកនាំរបស់គណៈកម្មាធិការ កាកបាទក្រហមអន្តរជាតិ “CIR” ដោយមានការសម្របសម្រួល ជាមួយតំណាងពិសេស របស់អគ្គលេខាធិការ ដោយមានការជួយឧបត្ថម្ភ តាមការដែលចាំបាច់អំពីអង្គការ មនុស្សធម៌អន្តរជាតិ សមស្របផ្សេងៗទៀត និង ពីហត្ថលេខីទាំងឡាយ ។

### មាត្រាទី ២២

ពាក្យថា “ជនស៊ីវិលជាប់ឃុំឃាំង” គឺសំដៅទលើគ្រប់បគ្គុល ដែលមិនមែនជាឈ្លើយសឹក ហើយដែលបានរួមចំណែក ដោយប្រការណាមួយក៏ដោយ ដល់ការតស៊ូដោយអាវុធ ឬការតស៊ូនយោបាយ ហើយត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួនដោយភាគី ណាមួយ ដោយសារការរួមចំណែករបស់ខ្លួននោះ ។

# ភាគទី ៧

## គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

### មាត្រាទី ២៣

បណ្តាគោលការណ៍ជាមូលដ្ឋាន ដោយរួមទាំងគោលការណ៍ ស្តីពីសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ក៏ដូចជាគោល-ការណ៍ស្តីពីលក្ខន្តិកៈរបស់កម្ពុជា ជាប្រទេសអព្យាក្រិតមួយ ហើយដែលត្រូវបញ្ចូល ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាថ្មីនោះ គឺមានចែងនៅក្នុង ឧបសម្ព័ន្ធទី ៥ ។

# ភាគទី ៨

## ការស្តារ និង កសាងឡើងវិញ

## មាត្រាទី ២៤

បណ្ដាហត្ថលេខីស្នើដ៏ទទូច ឱ្យសហគមន៍អន្តរជាតិ ផ្ដល់ការគាំទ្រផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការស្ដារ និង កសាងប្រទេសកម្ពុជាឡើងវិញ ដូចមានចែងនៅក្នុងសេចក្ដីប្រកាសដោយឡែកមួយ ។

# ភាគទី ៩

## បទបញ្ញត្តិចុងក្រោយ

## មាត្រាទី ២៥

ដោយទឹកចិត្តស្មោះត្រង់ និង ក្នុងស្មារតីសហប្រតិបត្តិការបណ្ដាហត្ថលេខី ទាំងឡាយត្រូវដោះស្រាយ ដោយសន្តិវិធីនូវរាល់ទំនាស់ដែលទាក់ទង ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី ២៦

ហត្ថលេខីទាំងឡាយស្នើសុំរដ្ឋដទៃផ្សេងទៀត អង្គការសហប្រជាជាតិ និង អង្គការដទៃទៀត ឱ្យចូលរួមសហការ និងជួយ ឧបត្ថម្ភក្នុងការអនុវត្ត កិច្ចព្រមព្រៀងនេះ និងក្នុងការបំពេញភារកិច្ចរបស់អ៊ុនតាក់ “UNTAC” ។

## មាត្រាទី ២៧

ហត្ថលេខីទាំងឡាយ ត្រូវធ្វើសហប្រតិបត្តិការដ៏ពេញលេញ ជាមួយអង្គការសហប្រជាជាតិ ដើម្បីធានាដល់ការអនុវត្តន៍ ភារកិច្ចរបស់គេ ដោយរួមទាំងការផ្ដល់បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិទាំងឡាយ និងដោយធានា និង ជួយសម្រួលដល់សេរីភាព ក្នុងការធ្វើដំណើរ និង ការទាក់ទងគ្នាក្នុងទឹកដី និង ឆ្លងកាត់ទឹកដីរៀងៗខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អ៊ុនតាក់ “UNTAC” ត្រូវអនុវត្តដោយគោរព ដោយសមស្រប នូវអធិបតេយ្យភាពនៃរដ្ឋទាំងអស់ដែលនៅជិតកម្ពុជា ។

## មាត្រាទី ២៨

១ - បណ្ដាហត្ថលេខីទាំងឡាយ ត្រូវធ្វើតាមដោយស្មោះស្ម័គ្រ នូវរាល់កាតព្វកិច្ច ដែលមានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ

ហើយត្រូវធ្វើសហប្រតិបត្តិការពេញលេញ ជាមួយអង្គការសហប្រជាជាតិ រួមទាំងការផ្ដល់ព័ត៌មានដែលអ៊ុនតាក់ "UNTAC" ត្រូវការក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

២ - ការចុះហត្ថលេខា តាំងនាមឱ្យប្រទេសកម្ពុជា ដោយបណ្ដាលសមាជិក អេសអិនស៊ី ត្រូវបានចាត់ទុកដូចជាការសន្យាគោរពដោយភាគី និង កងទ័ពកម្ពុជាទាំងអស់ ចំពោះប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី ២៩

ដោយមិនធ្វើឱ្យប៉ះពាល់ ដល់បុព្វសិទ្ធិរបស់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ហើយយោងតាមសំណើរបស់ លោក អគ្គលេខាធិការ សហប្រធានទាំងពីរ នៃសន្និសិទប៉ារីសស្ដីពីកម្ពុជា ក្នុងករណីដែលមានការរំលោភ ឬការគំរាម កំហែង និងមានការរំលោភដល់កិច្ចព្រមព្រៀងនេះ និងត្រូវធ្វើការពិគ្រោះគ្នា ដ៏សមស្របនានា ដល់ការគោរពសន្យាទាំងនេះ ។

## មាត្រាទី ៣០

កិច្ចព្រមព្រៀងនេះ និងចូលជាធរមាន ចាប់តាំងពីពេលចុះហត្ថលេខានេះទៅទៅ ។

## មាត្រាទី ៣១

កិច្ចព្រមព្រៀងនេះ នឹងត្រូវបើកចំហរសម្រាប់ការចូលរួម របស់រដ្ឋទាំងអស់ ។ ឯកសារផ្លូវការនៃការចូលរួម ត្រូវតំកល់ទុក ជាមួយរដ្ឋាភិលនៃសាធារណរដ្ឋបារាំង និង រដ្ឋាភិបាលនៃ សាធារណរដ្ឋឥណ្ឌូណេស៊ី ។ ចំពោះរដ្ឋនិមួយៗ ដែលយល់ព្រមចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងត្រូវចូលជាធរមានបញ្ញត្តិ ចាប់តាំងពីពេលតំកល់ឯកសារផ្លូវការសុំចូលរបស់ខ្លួន ។ បណ្ដារដ្ឋដែលបានសុំចូល ត្រូវជាប់បញ្ញត្តិទៅនឹងកាតព្វកិច្ចដូចគ្នានឹង បណ្ដាហត្ថលេខីដទៃទៀតដែរ ។

## មាត្រាទី ៣២

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលអត្ថបទធ្វើជាភាសាចិន - អង់គ្លេស - បារាំង - ខ្មែរ និង រុស្ស៊ី មានតម្លៃដូចគ្នានឹងត្រូវតំកល់រក្សាទុកជាមួយ រដ្ឋាភិបាលសាធារណរដ្ឋបារាំង និង រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី ដែលនឹងផ្ញើរនូវច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម ទៅជូនរដ្ឋាភិបាលនៃរដ្ឋផ្សេងៗទៀត ដែលបានចូលរួមនៅក្នុងសន្និសិទ ក្រុងប៉ារីសស្ដីពីកម្ពុជា និង ជូនទៅលោក អគ្គលេខាធីការសង្គការសហប្រជាជាតិ ។

ដើម្បីជាសក្ខីភាព បណ្ដាប្រតិភូពេញសមត្ថកិច្ច ដូចមាននាមខាងក្រោម ដែលបានទទួលសិទ្ធិត្រឹមត្រូវហើយនោះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅក្រុងប៉ារីស ថ្ងៃទី ម្ភៃបី (២៣) ខែតុលា (១០) ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបមួយ (១៩៩១) ។

# ឧបសម្ព័ន្ធទី ១

## ភារកិច្ចរបស់អាជ្ញាធរបណ្ដោះអាសន្ន នៃអង្គការសហប្រជាជាតិ នៅកម្ពុជា

“អ៊ុនតាក់”

## ជំពូក ក: នីតិក្រមរួម

១ - ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀងអ៊ុនតាក់ និងអនុវត្តអំណាចដែលចាំបាច់ ដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងនេះ ដោយគិតទាំង អំណាចដេលទាក់ទងទៅនឹងការរៀបចំ និង ការដឹកនាំការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ព្រមទាំង ទិដ្ឋភាព ទាំងឡាយនៃប្រទេសកម្ពុជា ដែលទាក់ទងទៅនឹងបញ្ហានេះ ។

២ - យន្តការខាងក្រោមនេះ នឹងត្រូវប្រើប្រាសដើម្បីដោះស្រាយបញ្ហាទាំងអស់ ទាក់ទងទៅនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ ដែលអាចកើតមានឡើង រវាងតំណាងពិសេស របស់លោកអគ្គលេខាធិការ និង ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ “អេសអិនស៊ី” :

ក - អេសអិនស៊ី ត្រូវជូនមតិណែនាំដល់អ៊ុនតាក់ ដែលត្រូវគោរពតាម មតិណែនាំនេះ ដរាបណាមានកុងសង់ស៊ុស ក្នុង ចំណោមសមាជិក អេសអិនស៊ី ហើយដរាបណាមតិណែនាំនោះ វាស្របនឹងទិសដៅ នៃកិច្ចព្រមព្រៀងនេះ

ខ - បើគ្មានកុងសុតស៊ុស ក្នុងចំណោមសមាជិក អេសអិនស៊ីនោះទេ ទោះបីជាមានការខិតខំប្រឹងប្រែង អស់លទ្ធភាព របស់ ប្រធានដោយ សម្ដេចនរោត្ដម សីហនុ ជាប្រធាន អេសអិនស៊ី នោះនឹងមានសិទ្ធិធ្វើសេចក្ដីសម្រេច ស្ដីពីការជូនមតិណែនាំ ដល់ អ៊ុនតាក់ ដោយយកចិត្តទុកដាក់ គិតគូរទាំងស្រុង ទៅដល់ទស្សនៈទាំងឡាយ ដែលបានសំដែងឡើង នៅក្នុងអេសអិនស៊ី ។ អ៊ុនតាក់នឹងគោរពតាមមតិណែនាំនោះ ក្នុងករណីមតិណែនាំនោះ សមស្របទៅនឹង ទិសដៅនៃកិច្ចព្រមព្រៀងនេះ

គ - បើសិនជាសម្ដេចនរោត្ដម សីហនុ ប្រធាន អេសអិនស៊ី តំណាងស្របច្បាប នៃអធិបតេយ្យភាពកម្ពុជា មិនអាចសម្រេច បានក្នុងករណីណាមួយនោះ សិទ្ធិនៃសេចក្ដីសម្រេចរបស់សម្ដេច នឹងផ្ទេរទៅឱ្យតំណាងពិសេស របស់អគ្គលេខាធិការ អ.ស.ប. ។ តំណាងពិសេស នឹងធ្វើសេចក្ដីសម្រេចចុងក្រោយ ដោយយកចិត្តទុកដាក់គិតគូរទាំងស្រុង ទៅដល់ទស្សនៈ ទាំងឡាយ ដែលបានសំដែងឡើងនៅក្នុង អេសអិនស៊ី

ឃ - សិទ្ធិអំណាចណា ដែលទាក់ទិនទៅ នឹងការអនុវត្ត កិច្ចព្រមព្រៀងនេះ ដែលបានប្រគល់ឱ្យអេសអិនស៊ី តាមកិច្ចព្រម ព្រៀង នឹង ត្រូវអនុវត្តដោយ កុងសុងស៊ុស ឬ បើសិនមិនអាចសម្រេចបាន កុងសុងស៊ុសនោះទេ សិទ្ធិអំណាចនោះនឹងត្រូវ

អនុវត្តដោយប្រធាន អេសអិនស៊ី ដោយយោងតាមនីតិក្រម ដែលបានរៀបរាប់ខាងលើ ។ ក្នុងករណី ដែលសម្តេច នរោត្តម សីហនុ ប្រធាន អេសអិនស៊ី តំណាងស្របច្បាប់ នៃអធិបតេយ្យភាពកម្ពុជា មិនអាចសម្រេចបាន ក្នុងករណីណាមួយនោះ សិទ្ធសម្រេចរបស់សម្តេចនេះនឹងត្រូវផ្ទេរទៅឱ្យ តំណាងពិសេសរបស់លោក អគ្គលេខាធិការ អ.ស.ប. ដែលអាចប្រកាន់យកនូវ វិធានការចាំបាច់នានា ។

ង - ក្នុងករណីទាំងអស់ តំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប. នឹងកំណត់ថា តើមតិណែនាំ ឬ វិធានការរបស់ អេសអិនស៊ី ស្របទៅនឹងកិច្ចព្រមព្រៀងឬទេ ។

៣ - តំណាងពិសេសនៃលោកអគ្គលេខាធិការ ឬ ប្រតិភូរបស់គាត់ ត្រូវចូលរួមអង្គប្រជុំទាំងឡាយរបស់ អេសអិនស៊ី ហើយត្រូវជូនដល់សមាជិកអេសអិនស៊ី អំពីរាល់ពត៌មានចាំបាច់ទាំងអស់ អំពីបណ្តាសេចក្តីសម្រេចរបស់អ៊ុនតាក់ ។

# ជំពូក ខ : រដ្ឋបាលស៊ីវិល

១ - ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀងនេះ អង្គការស្ថាប័ន និង ការិយាល័យរដ្ឋបាលទាំងអស់ ដែលមានតួនាទីក្នុង វិស័យការបរទេស ការពារជាតិ ហិរញ្ញវត្ថុ សន្តិសុខសាធារណៈ និងឃោសនាការ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ដោយផ្ទាល់របស់អ៊ុនតាក់ ដែលត្រូវត្រួតពិនិត្យតាម ការចាំបាច់ដើម្បីធានាអព្យាក្រិតភាព មួយដ៏ហ្មត់ចត់ ។

ក្នុងន័យនេះ តំណាងពិសេសរបស់លោកអគ្គលេខាធិការ ត្រូវកំណត់ថា អ្វីដែលចាំបាច់ ហើយគាត់អាចចេញបទបញ្ជាទៅដល់បណ្តាអង្គការ ស្ថាប័ន និង ការិយាល័យរដ្ឋបាលខាងលើនេះ ។ បទបញ្ជាទាំងនេះ អាចបញ្ជូនចេញទៅចំពោះភាគីកម្ពុជាទាំងអស់ ហើយអាចជាបទបញ្ញត្តិចំពោះភាគីកម្ពុជាទាំងអស់ផង ។

២ - ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀង តំណាងពិសេសរបស់លោកអគ្គលេខាធិការ ដោយមានការពិគ្រោះជាមួយ អេសអិនស៊ី ត្រូវកំណត់ថា តើអង្គការ ស្ថាប័ន និង ការិយាល័យរដ្ឋបាលណាទៀត ដែលអាចជះឥទ្ធិពលផ្ទាល់ ដល់លទ្ធផលនៃការបោះឆ្នោត ។ អង្គការស្ថាប័ន និង ការិយាល័យរដ្ឋាភិបាលអស់ទាំងនេះ ត្រូវដាក់នៅក្រោមការពិនិត្យ ឬ ការត្រួតពិនិត្យដោយផ្ទាល់របស់ អ៊ុនតាក់ ហើយត្រូវគោរពតាមការណែនាំ ទាំងឡាយរបស់អ៊ុនតាក់ ។

៣ - ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀង តំណាងពិសេសនៃលោកអគ្គលេខាធិការ ដោយមានការពិគ្រោះជាមួយ អេសអិនស៊ី និងពិនិត្យមើលថា តើអង្គការ ស្ថាប័ន និង ការិយាល័យរដ្ឋបាលណា អាចបន្តប្រតិបត្តិការតទៅទៀត ដើម្បីធានាដល់ជីវភាព ធម្មតាប្រចាំថ្ងៃ នៅប្រទេសកម្ពុជា ហើយបើសិនជាចាំបាច់ ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់ អ៊ុនតាក់ តាមការដែលអ៊ុតាក់យល់ថាចាំបាច់ ។

៤ - ស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀង សិទ្ធិអំណាចរបស់ តំណាងពិសេសនៃ លោកអគ្គលេខាធិការ ត្រូវមានអំណាចដើម្បី :

ក - តែងតាំងបុគ្គលិករបស់អង្គការសហប្រជាជាតិ នៅក្នុងអង្គការ ស្ថាប័ន និង ការិយាល័យរដ្ឋបាល របស់ភាគីកម្ពុជាទាំងអស់ ដែលនឹងមានសិទ្ធិចូលទាក់ទង ដោយគ្មានការហាមឃាត់ ជាមួយរាល់កិច្ចប្រតិបត្តិការផ្នែករដ្ឋបាល និង ពត៌មាន ។

ខ - ទាមទារឱ្យផ្លាស់ប្តូរទៅកន្លែងថ្មី ឬ ឱ្យដកហូតនូវបុគ្គលិកណាមួយ របស់បណ្តាអង្គការ ស្ថាប័ន និង ការិយាល័យរដ្ឋ-បាលនេះ ។

៥ - ក - ផ្អែកទៅលើពត៌មាន ដែលចែងនៅក្នុងមាត្រាទី ១ កថាខ័ណ្ឌ ៣ នៃឧបសម្ព័ន្ធ ២ តំណាងពិសេស របស់អគ្គលេខា-ធិការ ក្រោយពីមានការពិគ្រោះជាមួយភាគីកម្ពុជា នឹងកំណត់នូវ ប៉ូលិសស៊ីវិលជាចាំបាច់ ដើម្បីអនុវត្តច្បាប់នៅកម្ពុជា ។ ក្នុងករណីនេះ ភាគីកម្ពុជាទាំងអស់សន្យានឹងគោរព នូវការកំណត់ដែលធ្វើឡើង ដោយតំណាងពិសេសរបស់លោកអគ្គលេខាធិការ ។

ខ - ប៉ូលិសស៊ីវិលទាំងអស់ នឹងប្រតិបត្តិការក្រោមការពិនិត្យមើល ឬការត្រួតពិនិត្យរបស់ អ៊ុនតាក់ ដើម្បីធានាការរក្សាច្បាប់ និង សណ្តាប់ធ្នាប់ ដោយប្រសិទ្ធិភាព និង មិនលំអៀង ហើយសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ត្រូវបានគោរពទាំងស្រុង ។ ដោយមានការពិគ្រោះជាមួយ អេសអិនស៊ី អ៊ុនតាក់ ត្រូវពិនិត្យមើលនូវ ដំណើរការអនុវត្តច្បាប់ និង តុលាការដទៃទៀត នៅទូទាំងប្រទេសកម្ពុជា ដែលចាំបាច់ ដើម្បីធានាការសម្រេចនូវ ទិសដៅទាំងនោះ ។

៦ - បើតំណាងពិសេសរបស់ លោកអគ្គលេខាធិការយល់ថា ចាំបាច់ដោយមានការពិនិត្យ ពិគ្រោះជាមួយ អេសអិនស៊ី អ៊ុនតាក់ នឹងសើបអង្កេតការប្តឹងតវ៉ា នឹងការចោទប្រកាន់ស្តីពីសកម្មភាព ដេលរចនាសម្ព័ន្ធរដ្ឋបាល ដែលមានហើយនៅក្នុងប្រទេស កម្ពុជា ដែលមិនសមស្រប ឬ ដែលប្រឆាំងនឹង បណ្តាទិសដៅ នៃដំណោះស្រាយនយោបាយរួមនេះ ។ អ៊ុនតាក់ក៏ត្រូវមានអំណាច ស៊ើបអង្កេតបែបនេះ តាមគំនិតខ្លួនផ្ទាល់ដែរ ។ នៅពេលចាំបាច់ អ៊ុនតាក់នឹងចាត់វិធានការកែតម្រូវ ដ៏សមស្រប ។

## ជំពូក គ : មុខងារខាងយោធា

១ - អ៊ុនតាក់ នឹងពិនិត្យមើល តាមដាន និង បញ្ជាក់មើល ការដកកងកម្លាំងបរទេស ការឈបបាញ់ និង បណ្តាវិធានការទាក់ទងទាំងឡាយ ស្របតាមឧបសម្ព័ន្ធទី ២ រួមមាន :

ក - បញ្ជាក់ការដកកងកម្លាំងទីប្រឹក្សា និង បុគ្គលិកយោធាបរទេស គ្រប់ប្រភេទទាំងអស់ ព្រមទាំងអាវុធ គ្រាប់រំសេវ និង សម្ភារះរបស់គេ ចេញពីកម្ពុជា និង ការមិនវិលត្រឡប់របស់គេ ចូលមកកម្ពុជាវិញ ។

ខ - ទាក់ទងជាមួយរដ្ឋាភិបាលប្រទេសជិតខាង ស្តីពីព្រឹត្តិការណ៍ណាដែលកើតឡើងនៅក្នុង ឬ នៅជិតទឹកដីខ្លួន ដែលបណ្តាលឱ្យគ្រោះថ្នាក់ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ។

គ - តាមដាន ការបញ្ឈប់ជំនួយយោធាបរទេស ដល់ភាគីកម្ពុជាទាំងអស់ ។

ឃ - ស្វែងរកនិង រឹបអូសយកកន្លែងលាក់គ្រឿងសព្វាវុធ និង ភស្តុភារខាងយោធា ដែលគេលាក់ទុកទូទាំងប្រទេស ។

ង - ជួយបោសសំអាតមីន និង ដំណើរការកម្មវិធីហាត់ហ្វឹកហ្វឺន អំពីការបោសសំអាតមីន និង កម្មវិធីយល់ដឹងពីមីន ក្នុងចំណោមប្រជាជនកម្ពុជា ។

២ - អ៊ុនតាក់ និងពិនិត្យមើលការប្រមូលផ្តុំ និង ការដាក់ទីតាំងឡើងវិញ នៃកងកម្លាំងទាំងអស់ នៅកន្លែងជំរុំបន្ទាយ ដែលបានកំណត់ច្បាស់លាស់ ដោយផ្អែកទៅលើប្រតិទិន ប្រតិបត្តិការមួយ ដែលត្រូវបានព្រមព្រៀងគ្នា ស្របតាម ឧបសម្ព័ន្ធ ២ ។

៣ - បន្ទាប់កងកម្លាំងចូលទៅក្នុងជំរុំបន្ទាយ អ៊ុនតាក់ នឹងផ្តើមដំណើរការត្រួតពិនិត្យ និង កាត់បន្ថយសព្វាវុធ ដូចដែលបានបញ្ជាក់ក្នុង ឧបសម្ព័ន្ធ ។

៤ - អ៊ុនតាក់ ត្រូវចាត់វិធានការណ៍ជាចាំបាច់ ស្តីពីដំណើរការ រំសាយបណ្តើរៗ នូវកងកម្លាំងយោធានៃបណ្តាភាគី ស្របតាមឧបសម្ព័ន្ធ ២ ។

៥ - អ៊ុនតាក់ត្រូវជួយ តាមដែលចាំបាច់ដល់គណកម្មការ កាកបាទក្រហមអន្តរជាតិ ក្នុងការដោះលែងឈ្លើយសឹក និង ជនស៊ីវិលជាប់ឃុំឃាំងទាំងអស់ ។

# ជំពូក ឃ : ការបោះឆ្នោត

១ - អ៊ុនតាក់ ត្រូវរៀបចំ និង ដឹកនាំការបោះឆ្នោត ដែលមានចែងក្នុងភាគ ២ នៃកិច្ចព្រមព្រៀងនេះ ស្របតាមជំពូកនេះ និង ឧបសម្ព័ន្ធទី ៣ ។

២ - អ៊ុនតាក់ អាចពិគ្រោះជាមួយ អេសអិនស៊ី អំពីការរៀបចំ និង ការដឹកនាំដំណើរការបោះឆ្នោត ។

៣ - ក្នុងការអនុវត្តនូវការទទួលខុសត្រូវរបស់ខ្លួន ក្នុងដំណើរការបោះឆ្នោត សិទ្ធិអំណាចច្បាស់លាស់របស់ អ៊ុនតាក់រួមមានដូចតទៅនេះ :

ក - ដោយមានការពិគ្រោះមួយ អេសអិនស៊ី បង្កើតប្រពន្ធច្បាប់ ទំរង់បែបបទ និង វិធានការរដ្ឋបាលទាំងឡាយដែលចាំបាច់ សម្រាប់រៀបចំការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវនៅកម្ពុជា រាប់ទាំងការអនុម័តនូវ ច្បាប់បោះឆ្នោត និង បទបញ្ញា សីលធម៌មួយផង ដែលចាត់ចែងអំពីការចូលរួម ក្នុងការបោះឆ្នោត ធ្វើយ៉ាងណាឱ្យសមស្របនឹងការគោរពសិទ្ធិមនុស្ស និងការហាមឃាត់បង្ខិតបង្ខំ ឬការអូសទាញតាមមធ្យោបាយ ហិរញ្ញវត្ថុ

ដើម្បីជះឥទ្ធិពលទៅលើចំណូលចិត្តរបស់អ្នកបោះឆ្នោត ។

ខ - ផ្អាក ឬ លុបបំបាត់ចោល ដោយមានការពិគ្រោះជាមួយ អេសអិនស៊ី នូវបទបញ្ញត្តិច្បាប់ដែលមានស្រាប់ណា ដែលអាចធ្វើឱ្យបរាជ័យដល់កម្មវត្ថុ និង គោលបំណងនៃកិច្ចព្រមព្រៀងនេះ ។

គ - តាក់តែង និង អនុវត្តកម្មវិធីមួយ អប់រំដល់អ្នកបោះឆ្នោត រួមមានទិដ្ឋភាពទាំងអស់ នៃការបោះឆ្នោត ដើម្បីគាំទ្រដល់ដំណើរការបោះឆ្នោត ។

ឃ - តាក់តែង និង អនុវត្តប្រព័ន្ធចុះឈ្មោះ អ្នកបោះឆ្នោតមួយ ដែលជាដំណាក់កាលទី ១ នៃដំណើរការបោះឆ្នោត ដើម្បីធានាឱ្យអ្នកដែលមានសិទ្ធិបោះឆ្នោត មានឱកាសទៅចុះឈ្មោះ និង រៀបចំតទៅទៀតនូវ បញ្ជីចុះឈ្មោះ អ្នកបោះឆ្នោត ដែលបានបញ្ជាក់ហើយ ។

ង - តាក់តែង និង អនុវត្តប្រព័ន្ធចុះឈ្មោះមួយ នៃគណបក្សនយោបាយ និង បញ្ជីបេក្ខជន ។

ច - ធានាការចូលទាក់ទងដ៏សមរម្យ ជាមួយប្រព័ន្ធឃោសនា រួមទាំងកាសែត ទូរទស្សន៍ និង វិទ្យុ សម្រាប់គណបក្សនយោបាយទាំងអស់ ដែលប្រកួតប្រជែងក្នុងការបោះឆ្នោត ។

ឆ - អនុម័ត និង អនុវត្តវិធានការទាំងឡាយ ដើម្បីតាមដាន និង សម្រួលការចូលរួម របស់ប្រជាជនកម្ពុជា នៅក្នុងការបោះឆ្នោត យុទ្ធនាការឃោសនានយោបាយ និង ទំរង់បែបបទ នៃការបោះសន្លឹកឆ្នោត ។

ជ - តាក់តែង និង អនុវត្តប្រព័ន្ធរបៀបរបបបោះឆ្នោត និង វិធីបោះសន្លឹកឆ្នោត ដើម្បីធានាឱ្យអ្នក ដែលមានឈ្មោះបោះឆ្នោត មានលទ្ធភាពបោះឆ្នោត ។

ឈ - ដោយពិគ្រោះជាមួយ អេសអិនស៊ី បង្កើតឱ្យមានការរៀបចំ សម្របសម្រួលគ្នា ដើម្បីសម្រួលដល់វត្តមាន នៃអ្នកអង្កេតការណ៍បរទេស ដែលចង់មកអង្កេតយុទ្ធនាការឃោសនា និង ការបោះឆ្នោត ។

ញ - ដឹកនាំជាទូទៅ នៃការបោះឆ្នោត និង ការរាប់សន្លឹកឆ្នោត ។

ដ - ពិនិត្យមើល និង ស៊ើបអង្កេតអំពីការប្តឹងតវ៉ា ស្តីពីអំពើមិនត្រឹមត្រូវក្នុងការបោះឆ្នោត ព្រមទាំង នឹងចាត់វិធានការកែតម្រូវដ៏សមស្រប ។

ឋ - កំណត់ថា តើការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និង ត្រឹមត្រូវ ឬ ទេ ហើយបើសេរី និង ត្រឹមត្រូវហើយ ចេញសេចក្តីបញ្ជាក់ បញ្ជីឈ្មោះអ្នកដែលបានជាប់ឆ្នោត ត្រឹមត្រូវ ។

៤ - ក្នុងការអនុវត្តការ ទទួលខុសត្រូវរបស់ខ្លួនដូចមានចែងក្នុង ជំពូកនេះ អ៊ុនតាក់ ត្រូវបង្កើតប្រព័ន្ធការពារមួយ ដើម្បីជួយខ្លួនឱ្យធានាថា គ្មានការលួចបន្លំក្នុងដំណើរការបោះឆ្នោត រួមទាំងការរៀបចំឱ្យបណ្តាតំណាងកម្ពុជា ចូលសង្កេតបែបបទចុះឈ្មោះ និង បោះឆ្នោត ព្រមទាំងបង្កើតយន្តការរបស់ អ៊ុនតាក់ មួយ សម្រាប់ទទួលពាក្យបណ្តឹង និង សម្រេចអំពីការប្តឹងតវ៉ា ។

៥ - ប្រតិទិន សម្រាប់ដំណាក់កាលផ្សេងៗ នៃដំណើរការបោះឆ្នោត ត្រូវកំណត់ដោយ អ៊ុនតាក់ ដោយមានការពិគ្រោះជាមួយ អេសអិនស៊ី ដូចដែលមានចែងក្នុងកថខ័ណ្ឌទី ២ នៃជំពូកនេះ ។ ដំណើរការបោះឆ្នោត មានរយៈពេលមិនលើសពី ៩ ខែ ចាប់ពីពេលផ្តើមចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

៦ - ក្នុងការរៀបចំ និង ដឹកនាំ ដំណើរការបោះឆ្នោត អ៊ុនតាក់ ត្រូវខិតខំគ្រប់បែបយ៉ាង ដើម្បីធានាថា ប្រព័ន្ធ និង បែបបទដែលបានអនុម័ត នោះគឺគ្មានលំអៀងដាច់ខាត ទន្ទឹមគ្នានឹងការរៀបចំប្រតិបត្តិការ ទាំងឡាយខាងផ្នែករដ្ឋបាល ត្រូវឱ្យងាយស្រួល និង ប្រសិទ្ធិភាពបំផុត ដែលអាចធ្វើទៅបាន ។

# ជំពូក ខ : សិទ្ធិមនុស្ស

ស្របតាមមាត្រាទី ១៦ អ៊ុនតាក់ ត្រូវរៀបចំបែបបទទាំងឡាយសម្រាប់ :

ក - ការតាក់តែង និង ការអនុវត្តកម្មវិធីអបរំ អំពីសិទ្ធិមនុស្សមួយ ដើម្បីជំរុញការគោរព និង ការយល់ដឹងអំពីសិទ្ធិមនុស្ស ។

ខ - ការឃ្លាំមើលជាទូទៅ អំពីសិទ្ធិមនុស្ស ក្នុងដំណាក់កាល អន្តរកាល ។

គ - ការស៊ើបអង្កេត ការប្តឹងតវ៉ា អំពីសិទ្ធិមនុស្ស និង ការប្រកាន់យកនូវវិធានការកែតម្រូវ នៅទីណាដែលសមស្រប ។

# ឧបសម្ព័ន្ធទី ២

## ការដកកងកម្លាំង ការឈប់បាញ់ និង វិធានការពាក់ព័ន្ធ

## មាត្រាទី ១

## ការឈប់បាញ់

១ - គ្រប់ភាគីកម្ពុជាទាំងអស់ចាប់ពីនេះទៅហៅថា "បណ្តាភាគី" យល់ព្រមអនុវត្តការឈប់បាញ់ទាំងស្រុងមួយលើ ដីគោក លើទឹក និង លើអាកាស ។ ការឈប់បាញ់នេះ នឹងត្រូវអនុវត្តជាពីរដំណាក់កាល ។ នៅក្នុងដំណាក់កាលទី ១ ការឈប់បាញ់នឹងត្រូវអនុវត្ត ដោយមានការជួយគាំទ្រពីលោក អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ តាមរយៈការជួយឧបត្ថម្ភរបស់លោក ។ នៅក្នុងដំណាក់កាលទី ២ ដែលគប្បីចាប់ផ្តើមឱ្យបានឆាប់រហ័ស តាមដែលអាចធ្វោះទៅបាន ការឈប់បាញ់គ្នាត្រូវបានពិនិត្យមើលតាមដាន និង បញ្ជាក់ដោយ អ៊ុនតាក់ ។ មេបញ្ជាការផ្ទឹកយោធារបស់ អ៊ុនតាក់ ដោយមានពិគ្រោះពិភក្សាជាមួយបណ្តាភាគី និងកំណត់ពេលវេលា និង កាលបរិច្ឆេទពិតប្រាកដ នៃការចាប់ផ្តើមដំណាក់កាលទី ២ ។ កាលបរិច្ឆេទនេះ ត្រូវកំណត់យ៉ាងតិច ៤ សប្តាហ៍ មុនពេលចូលជាធរមាន នៃដំណាក់កាលទី ២ នេះ ។

២ - បណ្តាភាគីសន្យាថា ចាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះទៅ គេត្រូវគោរពតាមការឈប់បាញ់ ហើយត្រូវបញ្ជាក់កងកម្លាំង ប្រដាប់អាវុធរបស់ខ្លួនជាបន្ទាន់ ឱ្យដោះដៃចេញពីការប្រយុទ្ធ និង ជៀសវាងមិនធ្វើសកម្មភាពប្រទូសរ៉ាយ ហើយមិនដាក់ពង្រាយកងទ័ព ចលនាទ័ព ឬ ក៏ធ្វើសកម្មភាពណាមួយ ដែលនាំឱ្យពង្រីកទឹកដី ដែលខ្លួនកាន់កាប់ ឬ ដែលនាំឱ្យមានការប្រយុទ្ធគ្នាឡើងវិញ ក្នុងពេលរងចាំដំណាក់កាលទី ២ ចាប់ផ្តើមនោះ ។

គេបានឯកភាពគ្នាថា ពាក្យ "កងកម្លាំង" គឺរាប់បញ្ចូលកងទ័ពស្រួច ទ័ពខេត្ត ទ័ពស្រុក ស្វ័យត្រាណ ហើយនិងទ័ពជំនួយផ្សេងៗទាំងអស់ ។ នៅក្នុងរយៈពេលដំណាក់កាលទី ១ លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ នឹងផ្តល់នូវ ការឧបត្ថម្ភ របស់លោកដល់បណ្តាភាគី ដើម្បីជួយគេក្នុងការអនុវត្តន៍ ដំណាក់កាលទី ១ នេះ ។ បណ្តាភាគីសន្យាសុខចិត្ត ធ្វើសហប្រតិបត្តិការជាមួយលោកអគ្គលេខាធិការ ឬ ជាមួយតំណាងរបស់លោក ក្នុងការប្រើប្រាសការជួយឧបត្ថម្ភ របស់ លោកក្នុងបញ្ហានេះ ។

៣ - ភាគីទាំងនោះយល់ព្រមថា បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះភ្លាម ពត៌មានខាងក្រោម នឹងត្រូវផ្តល់អង្គការសហប្រជាជាតិ :

ក - កម្លាំងកងទ័ពទាំងអស់របស់ខ្លួន អង្គការចាត់តាំង ចំនួននិង កន្លែងពង្រាយទ័ពច្បាស់លាស់ នៅក្នុង និង ក្រៅប្រទេសកម្ពុជា ។ កន្លែងទិតាំងពង្រាយទ័ព ត្រូវគូសដៅលើផែនទីមួយ ដែលដៅទីតាំងទ័ពឈរជើងទាំងអស់ ទោះនៅទីនោះ មានទ័ពនៅកាន់កាប់ ឬ ក៏គ្មានក្តី ដោយរាប់ទាំងបណ្តាជរុំរៀបចំទ័ព បណ្តាមូលដ្ឋានផ្គត់ផ្គង់

និង ផ្លូវផ្គត់ផ្គង់ ។

ខ - បញ្ជីរួមនៃអាវុធ គ្រាប់រំសេវ និង សម្ភារៈដែលកងកម្លាំងរបស់ខ្លួនកាន់កាប់ ហើយនិងទីតាំងពិតប្រាកដនានា ដែលអាវុធ គ្រាប់រំសេវ និង សម្ភារៈទាំងនោះ កំពុងដាក់ពង្រាយ ។

គ - បញ្ជីកត់ត្រាលំអិតនៃចំការមីនរបស់ពួកគេ រាប់បញ្ចូលទាំងបែបមុន និង លក្ខណៈសម្បត្តិទាំងឡាយ នៃមីន ដែលគេដាក់ និង ពត៌មានពីមីន អន្ទាក់ប្រើដោយពួកគេ ព្រមទាំងពត៌មានដែលគេអាចទទួលបាន អំពីចំការមីន ឬ មីនអន្ទាក់ដែលដាក់ប្រើដោយភាគីឯទៀត ។

ឃ - កម្លាំងសារុបនៃកម្លាំងប៉ុលិសរបស់ខ្លួន អង្គការចាត់តាំងចំនួន និង កន្លែងពង្រាយកម្លាំងច្បាស់លាស់ ព្រមទាំងបញ្ជីរួមនៃអាវុធ គ្រាប់រំសេវ និង សម្ភារៈ ហើយនិង ទីកន្លែងពិតប្រាកដ ដែលអាវុធ គ្រាប់រំសេវ និង សម្ភារៈកំពុងដាក់ពង្រាយ ។

៤ - នៅពេលមកដល់កម្ពុជាភ្លាម ហើយមិនឱ្យតិចជាងមួយសប្តាហ៍ មុនចាប់ផ្តើមដំណាក់កាលទី ២ មេបញ្ជាការផ្នែកយោធានៃ អ៊ុនតាក់ ដោយមានការពិគ្រោះជាមួយភាគីទាំងឡាយ ត្រូវសម្រេចបញ្ចប់ផែនការរបស់អ៊ុនតាក់ សម្រាប់ប្រមូលផ្តុំ និងដាក់ក្នុងបន្ទាយនៃកងកម្លាំងរបស់ភាគីទាំងនោះ និងសម្រាប់រក្សាទុកអាវុធ គ្រាប់រំសេវ និង សម្ភារៈ ស្របតាមមាត្រា ៣ នៃឧបសម្ព័ន្ធនេះ ។ ផែនការនេះនឹងរាប់បញ្ចូល ទាំងការជ្រើសរើសតំបន់ប្រមូលផ្តុំ និងតំបន់បន្ទាយ ក៏ដូចជាប្រតិទិនដែលបានព្រមព្រៀងគ្នាហើយ ។ តំបន់បន្ទាយប្រមូលផ្តុំ ត្រូវរៀបចំឡើងសម្រាប់ ទំហំកងវរៈសេនាតូច ឬធំជាងនេះ ។

៥ - ភាគីទាំងអស់យល់ព្រម ចាត់វិធានការ ដើម្បីផ្តល់ពត៌មាន ដល់កងកម្លាំងរបស់ខ្លួនយ៉ាងតិច ២ សប្តាហ៍ មុនចាប់ផ្តើមដំណាក់កាលទី ២ ដោយប្រើគ្រប់មធ្យោបាយទាក់ទងគ្នា ដែលមានអំពីកាលបរិច្ឆេទ និង ពេលវេលា ដែលបានយល់ព្រមអំពីការចាប់ផ្តើមដំណាក់កាលទី ២ អំពីផែនការ ដែលបានយល់ព្រម សម្រាប់ការប្រមូលផ្តុំ និង ការដាក់ក្នុងបន្ទាយនៃកងកម្លាំងរបស់ពួកគេ និងសម្រាប់ការរក្សាទុកអាវុធ គ្រាប់រំសេវ និងសម្ភារៈរបស់ពួកគេ និងជាពិសេស អំពីកន្លែងពិតប្រាកដនៃតំបន់ប្រមូលផ្តុំ ដែល បណ្តាកងកម្លាំង ត្រូវទៅបង្ហាញខ្លួននោះ ។ ពត៌មានបែបនេះ ត្រូវបន្តផ្សព្វផ្សាយក្នុងរយៈពេល ៤ សប្តាហ៍ ក្រោយការចាប់ផ្តើម ដំណាក់កាលទី ២ ។

៦ - បណ្តាភាគីត្រូវគោរពប្រតិបត្តិតាមយ៉ាងទៀងទាត់បំផុត នូវការឈប់បាញ់គ្នា ហើយមិនត្រូវបង្កឡើងវិញ នូវការប្រទូស្តរ៉ាយណាតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាសឡើយ ។ បណ្តាមេបញ្ជាការរបស់ខ្លួនស្ថិតនៅក្នុងទីតាំងរៀងខ្លួន ដោយរងចាំធ្វើចលនាទៅតំបន់ប្រមូលផ្តុំ ដែលបានកំណត់ ហើយផ្អាកឈប់ធ្វើសកម្មភាពប្រទូស្តរ៉ាយ និង ពង្រាយទ័ព ឬចលនា ឬធ្វើអំពើណាមួយដែលនឹងពង្រីកទឹកដីដែលខ្លួនត្រួតត្រា ឬដែលអាចនាំទៅដល់ ការប្រយុទ្ធគ្នាឡើងវិញនោះ ។

# មាត្រាទី ២

## ប្រព័ន្ធទំនាក់ទំនងក្រុមការងារយោធាចំរុះ

ក្រុមការងារយោធាចំរុះមួយ នឹងត្រូវបង្កើតឡើង ដើម្បីដោះស្រាយនូវរាលបញ្ហា ដែលអាចកើតមានឡើង ក្នុងការអនុវត្តន៍ នូវការឈប់បាញ់គ្នា ។ ក្រុមនេះនឹងត្រូវដឹកនាំ ដោយនាយទាហានជាន់ខ្ពស់បំផុត របស់ អ.ស.ប. នៅកម្ពុជា ឬ ដោយអ្នកតំណាងរបស់គាត់ ។ ភាគីនិមួយៗ ព្រមព្រៀងចាត់តាំង នូវនាយទាហានម្នាក់ថ្នាក់ឧត្តមសេនីយត្រី ឬ ថ្នាក់ស្មើគ្នា ដើម្បីបំរើការក្នុងក្រុមការងារយោធាចំរុះ ។ សមាសភាគ វិធីប្រតិបត្តិការ និង កន្លែងជួបជុំនៃក្រុមនេះ ត្រូវសម្រេចកំណត់ឡើង ដោយនាយទាហានជាន់ខ្ពស់បំផុតរបស់ អ.ស.ប. ដោយមានការពិគ្រោះជាមួយភាគីទាំងឡាយ ។ ការរៀបចំប្រព័ន្ធទាក់ទងដូចគ្នានេះ នឹងត្រូវបានធ្វើឡើងនៅកំរិតមេបញ្ជាការយោធាថ្នាក់ក្រោមៗ ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងនៅនឹងកន្លែង ។

# មាត្រាទី ៣

## ការប្រមូលផ្តុំ ការស្នាក់នៅក្នុងបន្ទាយនៃកងកម្លាំង របស់បណ្តាភាគី និង ការរក្សាទុកអាវុធ គ្រាប់រំសេវ និង សម្ភារៈរបស់គេ

១ - ស្របទៅតាមប្រតិទិនប្រតិបត្តិការ ដូចបានលើកឡើងក្នុង កថាខ័ណ្ឌទី ៤ នៃមាត្រាទី ១ របស់ឧបសម្ព័ន្ធនេះ កងកម្លាំងទាំងអស់នៃបណ្តាភាគី ដែលពុំទាន់បានទៅដល់តំបន់បន្ទាយស្នាក់នៅនោះ ត្រូវទៅជួបជុំគ្នា នៅតំបន់ប្រមូលផ្តុំ ដែលកំណត់ទុកដែលនឹងត្រូវបានរៀបចំឡើង និងដាក់ឱ្យដំណើរការ ដោយផ្នែកយោធានៃ អ៊ុនតាក់ ។ តំបន់ប្រមូលផ្តុំទាំងនេះត្រូវរៀបចំឡើង និងឱ្យដំណើរការបាន មិនឱ្យតិចជាងមួយសប្តាហ៍ មុនការចាប់ផ្តើមដំណាក់កាលទី ២ ឡើយ ។ ភាគីទាំងអស់ព្រមព្រៀងថា នឹងរៀបចំឱ្យកងកម្លាំងទាំងអស់ របស់ខ្លួនជាមួយនឹងអាវុធ គ្រាប់រំសេវ និង សម្ភារៈធ្វើដំណើរទៅកាន់តំបន់ប្រមូលផ្តុំ ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីការចាប់ផ្តើម ដំណាក់កាលទី ២ ទៅ ។ បុគ្គលិកទាំងអស់ ដែលបានទៅដល់តំបន់ត្រមូលផ្តុំ បន្ទាប់មកនឹងត្រូវជូនដំណើរដោយបុគ្គលិកផ្នែកយោធារបស់ អ៊ុនតាក់ ដោយនាំជាមួយទាំងអាវុធ គ្រាប់រំសេវ និង សម្ភារៈរបស់ខ្លួន ឆ្ពោះទៅតំបន់បន្ទាយដែលបានកំណត់ទុក ។ ភាគីទាំងអស់យល់ព្រមថា ធ្វើយ៉ាងណាឱ្យបុគ្គលិក ដែលធ្វើដំណើរទៅកាន់ តំបន់ប្រមូលផ្តុំ និងអាចធ្វើទៅបាន ដោយសុវត្ថិភាពទាំងស្រុង និង ដោយគ្មានការរំខានណាឡើយ ។

២ - លើមូលដ្ឋាន នៃពត៌មានដែលបានផ្តល់ឱ្យស្របទៅតាមកថាខ័ណ្ឌទី ៣ នៃមាត្រាទី ១ នៃឧបសម្ព័ន្ធនេះ អ៊ុនតាក់ ត្រូវបញ្ជាក់ប្រាប់ថា ដំណើរការប្រមូលផ្តុំ និង ចូលក្នុងបន្ទាយបានរួចរាល់ចប់សព្វគ្រប់ហើយ ស្របតាមផែនការដែលបានលើកឡើងនៅក្នុងកថាខ័ណ្ឌ ៤ នៃមាត្រាទី ១ នៃឧបសម្ព័ន្ធនេះ ។ អ៊ុនតាក់នឹងខិតខំបង្ហើយដំណើរការទាំងនេះក្នុងរយៈពេល ៤ សប្តាហ៍ចាប់ពីពេលចាបើផ្តើមដំណាក់កាលទី ២ ។ នៅពេលដែលការប្រមូលផ្តុំ និង ការចលនាកងកម្លាំងទាំងអស់ ទៅតំបន់បន្ទាយស្នាក់នៅបានបញ្ចប់សព្វគ្រប់រៀងៗខ្លួនហើយ មេបញ្ជាការផ្នែកយោធារបស់ អ៊ុនតាក់ ត្រូវជូនពត៌មាននេះទៅរាល់ភាគីទាំង ៤ ។

៣ - ភាគីទាំងឡាយយល់ព្រមគ្នាថា នៅពេលដែលកងកម្លាំងរបស់ខ្លួន ចូលមកដល់កន្លែងបន្ទាយដែលបានកំណត់ទុកហើយ មេបញ្ជាការរបស់ខ្លួន ត្រូវបញ្ជាប់ដល់បុគ្គលិករបស់ខ្លួន ឱ្យប្រគល់ជាបន្ទាន់នូវអាវុធ គ្រាប់រំសេវ និង សម្ភារៈទាំងអស់ទៅ អ៊ុនតាក់ ដើម្បីគ្រប់គ្រងរក្សាទុក ។

៤ - អ៊ុនតាក់នឹងត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់អាវុធ គ្រាប់រំសេវ និង សម្ភារៈដែលត្រូវប្រគល់ឱ្យខ្លួន ដោយផ្ទៀងផ្ទាត់នឹងបញ្ជីដូចមាននិយាយក្នុងកថាខ័ណ្ឌ ៣ ខ នៃមាត្រាទី ១ របស់ ឧបសម្ព័ន្ធនេះ ដើម្បីពិនិត្យអោយឃើញថា អាវុធ គ្រាប់រំសេវ និង សម្ភារៈទាំងអស់កាន់កាប់ដោយភាគីទាំងឡាយ បានត្រូវប្រគល់ឱ្យ អ៊ុនតាក់ គ្រប់គ្រងហើយ ។

## មាត្រាទី ៤

## ការផ្គត់ផ្គង់ភស្តុភារឡើងវិញ ដល់កងកម្លាំងក្នុងរយៈពេលស្ថិតក្នុងបន្ទាយ

ផ្នែកយោធារបស់ អ៊ុនតាក់ ត្រូវត្រួតពិនិត្យការផ្គត់ផ្គង់ភស្តុភារឡើងវិញ ដល់កងកម្លាំងទាំងអស់ នៃបណ្តាភាគីរយៈពេលប្រមូលផ្តុំ និងដំណើរស្នាកនៅក្នុងបន្ទាយ ។ ការផ្គត់ផ្គង់ភស្តុភារឡើងវិញទាំងនេះ គឺកំណត់តែចំពោះសម្ភារៈ ដែលគ្មានលក្ខណៈជាគ្រឿងប្រហារជីវិត ដូចជាស្បៀង ទឹក សម្លៀកបំពាក់ និង ថ្នាំពេទ្យ ក៏ដូចជាការព្យាលបាលជំងឺ ។

## មាត្រាទី ៥

## ការដោះស្រាយជាចុងក្រោយ ពីរឿងកងកម្លាំង របស់បណ្តាភាគី ព្រមទាំងអាវុធ គ្រាប់រំសេវ និង សម្ភារះរបស់គេ

១ - ដើម្បីពង្រឹងទិសដៅ នៃដំណោះស្រាយនយោបាយរួម បន្ថយគ្រោះថ្នាក់នៃការវិលត្រឡប់ ទៅរកសង្គ្រាមឡើងវិញ ធ្វើអោយសភាពការណ៍ សន្តិសុខមានស្ថិរភាព និង កសាងជំនឿទុកចិត្តគ្នានៅក្នុងចំណោម ភាគីនៅក្នុងជំលោះនោះ ភាគីទាំងអស់សុខចិត្តយល់ព្រមឱ្យដំណើរការជាដំណាក់ និង តុល្យភាព នូវការរំសាយកងកម្លាំងយោធា របស់ខ្លួនយ៉ាងតិច ៧០ ភាគរយ ។ ដំណើរការនេះនឹងត្រូវអនុវត្តសមស្របទៅនឹងផែនការលំអិតមួយ ដែលនឹងត្រូវរៀបចំដោយ អ៊ុនតាក់ ដោយផ្អែកទៅលើពត៌មាន ដែលមានចែងក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ និង ដោយមានការពិគ្រោះគ្នា ជាមួយបណ្តាភាគី ។ ដំណើរការរំសាយនេះ ត្រូវធ្វើឱ្យហើយសព្វគ្រប់ នៅមុនបញ្ចប់ការចុះបញ្ជីឈ្មោះ សម្រាប់ការបោះឆ្នោត និង នៅថ្ងៃណាមួយដែលត្រូវ កំណត់ដោយតំណាងពិសេ របស់លោកអគ្គលេខាធិការ ។

២ - បណ្តាភាគីកម្ពុជា ប្តេជ្ញាចិត្តដោយខ្លួនឯង រំសាយកងកម្លាំងរបស់ខ្លួនទាំងអស់ ដែលនៅសេសសល់មុន ឬ ក្រោយបន្តិចនៃការបោះឆ្នោត ហើយបើក្នុងកំរិតណា ការរំសាយទាំងស្រុងនោះ មិនអាចសម្រេចបានទេ ត្រូវគោរព និង ប្រព្រឹត្តតាមនូវសេចក្តីសម្រេចណា ដែលរដ្ឋាភិបាលថ្មីជាប់ឆ្នោត អនុវត្តយកកម្លាំងទាំងនោះ បញ្ចូលទៅក្នុងកងទ័ពជាតិថ្មី ជាផ្នែកឬទាំងស្រុងស្របតាមមាត្រាទី ១២ នៃកិច្ចព្រមព្រៀងនេះ ។ ដោយយោងទៅនឹងកថាខ័ណ្ឌ ១ នៅពេលរំសាយកងកម្លាំងចប់សព្វគ្រប់ហើយ ភាគីកម្ពុជា និង តំណាងពិសេសរបស់ លោកអគ្គលេខាធិការ ត្រូវត្រួតពិនិត្យដោយហ្មត់ចត់ឡើងវិញ នូវការដោះស្រាយចុងក្រោយនៃកងកម្លាំងដែលនៅសេសសល់នៅក្នុងបន្ទាយ ក្នុងទិសដៅកំណត់យកចំណុចណាមួយខាងក្រោមដើម្បីអនុវត្ត :

ក - បើសិនជាភាគីទាំងឡាយ យល់ព្រមបន្តរធ្វើការរំសាយ កងកម្លាំងដែលនៅសេសសល់ ក្នុងបន្ទាយទាំងស្រុង ឬ មួយចំនួន ជាការប្រសើរនៅមុន ឬ ផ្ទុយទៅវិញ ក្រោយការបោះឆ្នោតបន្តិច តំណាងពិសេសនឹងរៀបចំប្រតិទិនមួយ សម្រាប់ការងារនោះ ដោយពិគ្រោះជាមួយបណ្តាភាគី ។

ខ - បើសិនជាការរំសាយទាំងស្រុងនូវកងកម្លាំងទាំងអស់ ដែលនៅសេសសល់មិនអាចប្រព្រឹត្តទៅបានមុន ឬ ក្រោយបន្តិចនៃការបោះឆ្នោតនោះទេ បណ្តាភាគីត្រូវអនុវត្តបាននូវការប្រគល់កងកម្លាំង ដែលនៅសេសសល់ទាំងអស់របស់ខ្លួនក្នុងបន្ទាយ ទៅឱ្យរដ្ឋាភិបាលថ្មីជាប់ឆ្នោត ស្របតាមមាត្រា ១២ នៃកិច្ចព្រមព្រៀងនេះ ដើម្បីពិនិត្យបញ្ចូលក្នុងកងទ័ពជាតិថ្មីមួយ ។ ភាគីទាំងឡាយបន្តរយល់ព្រមថា កងកម្លាំងទាំងឡាយណា ដែលមិនបញ្ចូលទៅក្នុងកងទ័ពជាតិថ្មីនោះ នឹងត្រូវរំសាយជាបន្ទាន់ស្របតាមផែនការមួយដែងរៀបចំឡើង ដោយដំណាងពិសេស ។ ស្តីពីដំណោះស្រាយចុងក្រោយ នៃកងកម្លាំងដែលនៅសេសសល់ និង អាវុធ គ្រាប់រំសេវ និង សម្ភារៈទាំងអស់នៅពេលខ្លួនរៀបចំចេញពីកម្ពុជា អ៊ុនតាក់ ត្រូវរក្សាទុកនូវសិទ្ធិដែលចាំបាច់ ដើម្បីធានាការផ្ទេរដោយមានសណ្តាប់ធ្នាប់ ទៅឱ្យរដ្ឋាភិបាលថ្មីជាប់ឆ្នោត នូវភារកិច្ចដែលខ្លួនបានអនុវត្តក្នុងដំណាក់កាលអន្តរកាល ។

៣ - ជាចាំបាច់ អ៊ុនតាក់ នឹងជួយដល់កងកម្លាំង ដែលបានរំសាយមុនពេលបោះឆ្នោត ឱ្យចូលក្នុងជីវផាពស៊ីវិល ។

៤ - ក - អ៊ុនតាក់និងបន្តរត្រួតពិនិត្យ និង គ្រប់គ្រងអាវុធ គ្រាប់រំសេវ និង សម្ភារៈទាំងអស់ របស់បណ្តាភាគី ក្នុងដំណាក់កាលអន្តរកាល ។

ខ - នៅពេលដែលរំសាយកងកម្លាំងនៅក្នុងបន្ទាយស្របតាមកថាខ័ណ្ឌ ១ ខាងលើនេះ អ៊ុនតាក់ត្រូវធ្វើការកាត់បន្ថយក្នុងពេលជាមួយគ្នា នូវអាវុធគ្រាប់រំសេវ និង សម្ភារៈដែលបានរក្សាទុក នៅកន្លែងក្នុងតំបន់បន្ទាយ ។ ចំពោះកងកម្លាំងដែល នៅសេសសល់ក្នុងតំបន់បន្ទាយ ការចូលទៅយកអាវុធ គ្រាប់រំសេវ និង សម្ភារៈរបស់ខ្លួន ត្រូវតែផ្អែកទៅលើការអនុញ្ញាតច្បាស់លាស់ ពីតំណាងពិសេស របស់លោកអគ្គលេខាធិការ ។

គ - បើសិនជាមានការរំសាយកងកម្លាំងយោធាបន្តទៀត ដោយយោងតាមកថាខ័ណ្ឌ ២ "ក" ខាងលើ អ៊ុនតាក់នឹងធ្វើការកាត់បន្ថយតាមសមាមាត្រដូចគ្នា នូវអាវុធ គ្រាប់រំសេវ និង សម្ភារៈដែលរក្សាទុកនៅកន្លែងក្នុង

តំបន់បន្ទាយ ។

ឃ - ការដោះស្រាយចុងក្រោយនូវអាវុធ គ្រាប់រំសេវ និង សម្ភារៈទាំងអស់ នឹងត្រូវសម្រេចកំណត់ដោយរដ្ឋាភិបាល ដែលលេចចេញពី ការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវស្របតាមមាត្រាទី ១២ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី ៦

## ការពិនិត្យបញ្ជាក់អំពីការដកចេញពីកម្ពុជា និង ការមិនត្រឡប់វិញ នៃកងកម្លាំងបរទេសគ្រប់ប្រភេទទាំងអស់

១ - ក្នុងរយៈពេលមិនតិចជាងពីរសប្តាហ៍ មុនពេលចាប់ផ្តើមដំណាក់កាលទី ២ នាការឈប់បាញ់ គេត្រូវផ្តល់ឱ្យ អ៊ុនតាក់ នូវព័ត៌មានលំអិតជា លាយលក្ខណ៍អក្សរស្តីពីការដកកងកម្លាំងបរទេស ។ ពត៌មានទាំងនេះ ត្រូវរួមមានចំណុចដូចតទៅនេះ ។

ក - កម្លាំងសារុបការចាត់តាំង និង ការដាក់ពង្រាយនៃកងកម្លាំងទាំនេះ ។

ខ - បញ្ជីសារុបនៃគ្រឿងអាវុធ គ្រាប់រំសេវ និង សម្ភារៈដែលកងកម្លាំងទាំងនេះកាន់កាប់ និង កន្លែងទីតាំងពិតប្រាកដនៃរបស់ទាំងអស់នោះ ។

គ - ផែនការដកទ័ពចេញ "អនុវត្តហើយក្តី ឬ ដែលនឹងត្រូវអនុវត្ត" រួមទាំងផ្លូវដកទ័ពចេញ ចំណុចឆ្លងព្រំដែន និង ពេលវេលាចាកចេញពីកម្ពុជា ។

២ - លើមូលដ្ឋាននៃពត៌មាន ដែលគេបានផ្តល់ឱ្យ ស្របទៅតាមកថាខ័ណ្ឌទី ១ ខាងលើនេះ អ៊ុនតាក់ នឹងធ្វើការស្រាវជ្រាវ និង ស៊ើបអង្កេតតាមរបៀប ដែលខ្លួនយល់ថាសមស្រប ។

ភាគីដែលបានផ្តល់ពត៌មានឱ្យ ត្រូវផ្តល់បុគ្គលិករបស់ខ្លួន ឱ្យចុះអមដំណើរអ្នកធ្វើការស្រាវជ្រាវ អង្កេតរបស់អ៊ុនតាក់ ។

៣ - នៅពេលមានសេចក្តីបញ្ជាក់ថា មានវត្តមានកងកម្លាំង បរទេសណាមួយនោះ អ៊ុនតាក់ នឹង ដាក់ពង្រាយបុគ្គលិកយោធារបស់ខ្លួនជាបន្ទាន់ ជាមួយកងកម្លាំងបរទេស ហើយអមដំណើរកងកម្លាំងបរទេសទាំងនោះរហូតទាល់តែដកចេញផុតពីទឹកដីកម្ពុជា ។ អ៊ុនតាក់ ក៏នឹងបង្កើតកន្លែងត្រួតពិនិត្យ ណៅតាមផ្លូវដកកងកម្លាំង ចំណុចឆ្លងព្រំដែន និង អាកាសយានដ្ឋាន ដើម្បីពិនិត្យបញ្ជាក់ ពីការដកកងកម្លាំង និង ធានាថាកងកម្លាំងបរទេស គ្រប់ប្រភេទមិនវិលត្រឡប់មកវិញទេ ។

៤ - ក្រុមការងារយោធាចម្រុះ ដែលមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះ ត្រូវជួយអ៊ុនតាក់ ក្នុងការអនុវត្តន៍ភារកិច្ចដូច

ចែងខាងលើនេះ ។

## មាត្រា ៧

## ការបញ្ឈប់ជំនួយផ្នែកយោធា ពីខាងក្រៅដល់ភាគីកម្ពុជាទាំងអស់

១ - ភាគីទាំងអស់សន្យាថា ចាំតាំងពីពេលចុះហត្ថលេខាលើ កិច្ចព្រមព្រៀងនេះទៅ ឈប់ទទួលយក ឬស្វែងរកជំនួយយោធាពីក្រៅណាទាំងអស់ រួមទាំងអាវុធ គ្រាប់រំសេវ និង សម្ភារៈលឹកមកពីប្រភពខាងក្រៅ ។

២ - ហត្ថលេខីទាំងឡាយ ដែលទឹកដីប្រទេសខ្លួនស្ថិតជាប់នឹងប្រទេសកម្ពុជា គឺរដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយឡាវ រាជាណាចក្រថៃឡង់ និង សាធារណរដ្ឋសង្គមនិយមវៀតណាម សន្យាថានឹង :

ក - ហាមឃាត់មិនឱ្យទឹកដី នៃប្រទេសរៀងៗខ្លួន រាប់ទាំងដែនដី ដែនសមុទ្រ និង ដែនអាកាស កុំឱ្យគេប្រើប្រាសក្នុងបំណងផ្តល់ ជំនួយយោធាតាមរូបភាពណាមួយ ឱ្យដល់ភាគីកម្ពុជាណាឡើយ ។ ការផ្តល់ភស្តុភារជាថ្មី ដូចជា ស្បៀង ទឹក សម្លៀកបំពាក់ និងសម្ភារៈពេទ្យ តាមរយៈប្រទេសទាំងនោះ នឹងត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវជាកម្មវត្ថុ នៃការពិនិត្យមើលរបស់អ៊ុនតាក់ ពេលមកដល់កម្ពុជា ដោយមិនធ្វើឱ្យប៉ះពាល់ដល់ ប្រការនៃអនុកថាខ័ណ្ឌ "គ" ខាងក្រោមនេះ ។

ខ - បញ្ជាក់ជាលាយលក្ខណ៍អក្សរ ទៅដល់មេបញ្ជាការនៃ ផ្នែកយោធារបស់អ៊ុនតាក់ មិនឱ្យលើសពី ៤ សប្តាហ៍ បន្ទាប់ពីចាប់ផ្តើមដំណាក់កាលទី ២ នៃការឈប់បាញ់គ្នាថា គ្មានកងកម្លាំង អាវុធ គ្រាប់រំសេវ ឬសម្ភារៈយោធារបស់ភាគីកម្ពុជាណាមួយមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួនឡើយ ។

គ - ទទួលយកមន្ត្រីទំនាក់ទំនង របស់អ៊ុនតាក់ម្នាក់ នៅក្នុងរដ្ឋធានីរៀងៗខ្លួន និងចាត់តាំងនាយកទាហានម្នាក់ ដែលមានឋានន្តរស័ក្តិជា វរៈសេនីយឯក ឬឋានៈប្រហាក់ប្រហែលគ្នានេះ មិនឱ្យហួសពី ៤ សប្តាហ៍ បន្ទាប់ពិចាប់ផ្តើមដំណាក់កាលទី ២ នៃការឈប់បាញ់គ្នា ដើម្បីជួយអ៊ុនតាក់ ក្នុងការស៊ើបអង្កេតរាល់ពាក្យបណ្តឹងតវ៉ា ដោយគោរពយ៉ាងត្រឹមត្រូវចំពោះ អធិបតេយ្យភាពរបស់គេរៀងៗខ្លួនថា កំពុងមានសកម្មភាពកើតឡើងនៅក្នុងទឹកដីរបស់ខ្លួន ដែលផ្ទុយទៅនឹងប្រការទាំងឡាយ នៃដំណោះស្រាយនយោបាយរួម ។

៣ - ដើម្បីឱ្យអ៊ុនតាក់អាចតាមដាន ការបញ្ឈប់ជំនួយបរទេស ទៅឱ្យភាគីកម្ពុជាទាំងអស់ បណ្តាភាគីព្រមព្រៀងថា បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងគ្នានេះ គេនឹងផ្តល់ជូនដល់អ៊ុនាតក់ នូវព័ត៌មានដែលគេមានអំពីផ្លូវ និង មធ្យោបាយដែលអាវុធ គ្រាប់រំសេវ និង សម្ភារៈយោធាបានផ្តល់ទៅឱ្យភាគីណាមួយកន្លងមក ។ បន្ទាប់ពិដំណាក់កាលទី ២ ការឈប់បាញ់គ្នាចាប់ផ្តើមភ្លាមនោះ អ៊ុនតាក់នឹងអនុវត្តវិធានការជាក់ស្តែងដូចតទៅ៖

ក - បង្កើតកន្លែងត្រួតពិនិត្យតាមផ្លូវ និង នៅកន្លែងជ្រើសរើសមួយចំនួន តាមបណ្តោយព្រំដែន ខាងកម្ពុជា និង នៅព្រលានយន្តហោះ ក្នុងប្រទេសកម្ពុជា ។

ខ - យាមល្បាតតាមឆ្នេរសមុទ្រ និង តាមដងផ្លូវទឹកទាំងឡាយ ក្នុងប្រទេសកម្ពុជា ។

គ - រក្សាក្រុមចល័ត នៅកន្លែងយុទ្ធសាស្ត្រនៅក្នុងប្រទេសកម្ពុជា ដើម្បីយាមល្បាត និង ស៊ើបអង្កេតការចោទប្រកាន់ អំពីការផ្តល់អាវុធទៅឱ្យបណ្តាភាគីណាមួយ ។

## មាត្រា ៨

## កន្លែងលាក់អាវុធ និង សម្ភារៈយោធា

១ - ដើម្បីធ្វើឱ្យសភាពការណ៍ សន្តិសុខមានស្ថិរភាព កសាងជំនឿទុកចិត្ត និង បន្ថយការផ្តល់អាវុធ និង សម្ភារៈយោធាទូទាំងប្រទេសកម្ពុជា ភាគីនិមួយៗ ព្រមព្រៀងផ្តល់ដល់បញ្ជាការ ផ្នែកយោធារបស់ អ៊ុនតាក់ នូវព័ត៌មានទាំងឡាយដែលខ្លួនមាន រាប់ទាំងផែនទីដែលមានគំនូសបញ្ជាក់ច្បាស់ អំពីកន្លែងលាក់អាវុធ និង សម្ភារៈសឹកដែលគេដឹង ឬដែលគេសង្ស័យនៅទូទាំងប្រទេសកម្ពុជា ឱ្យបានមុនកាលបរិច្ឆេទ ដែលកំណត់ដោយបញ្ជាការយោធារបស់ អ៊ុនតាក់នេះ ។

២ - លើមូលដ្ឋានពត៌មានដែលបានទទួល ផ្នែកយោធារបស់ អ៊ុនតាក់ ក្រោយថ្ងៃដែលបានចែងនៅក្នុងកថាខ័ណ្ឌ ១ ត្រូវពង្រាយក្រុមពិនិត្យ បញ្ជាក់ដើម្បីទៅសើបអង្កេតតាមរបាយការណ៍និមួយៗ និង បំផ្លាញកន្លែងលាក់អាវុធនិមួយៗដែលបានរកឃើញ ។

## មាត្រា ៩

## គ្រឿងយុទ្ធភណ្ឌ ដែលមិនទាន់ផ្ទុះ

១ - ក្រោយពេលមកដល់ប្រទេសកម្ពុជាភ្លាម ផ្នែកយោធារបស់ អ៊ុនតាក់ ជាជំហានដំបូងត្រូវធ្វើយ៉ាងណា ឱ្យគូសចំណាំយ៉ាងច្បាស់លាស់រាល់ចំការមីនដែលបានដឹងហើយ ។

២ - ភាគីទាំងអស់ព្រមព្រៀងគ្នាថា ក្រោយពីការបញ្ចប់ដំណើរការប្រមូលផ្តុំ និងដាក់ក្នុងជំរុំហើយ ស្របតាមមាត្រាទី ៣ នៃឧបសម្ព័ន្ធនេះ ភាគីទាំងនេះនឹងរៀបចំឱ្យមាន ក្រុមបោសសំអាតមីន ដែលត្រូវចាកចេញពីតំបន់បន្ទាយស្នាក់នៅដោយនៅក្រោមការត្រួតពិនិត្យរបស់បុគ្គលិកយោធា របស់អ៊ុនតាក់ ដើម្បីជួយអ៊ុនតាក់ដកហូតយកចេញ ឬក៏ធ្វើឱ្យលែងផ្ទុះ គ្រឿងយុទ្ធភ័ណ្ឌទាំងឡាយ ដែលនៅសេសសល់ហើយមិនទាន់ផ្ទុះ ។ គ្រាប់មីនឬវត្ថុទាំងអស់នេះ ដែលមិន

អាចដក ឬ ដោះចេញ ឬក៏ធ្វើឱ្យលែងផ្ទុះបាន នឹងត្រូវគូសចំណាំ យ៉ាងច្បាសតាមបែបផែនមួយ ដែលតាក់តែងឡើង ដោយផ្នែកយោធារបស់ អ៊ុនតាក់ ។

៣ - អ៊ុនតាក់ត្រូវ :

ក - ចាត់តាំងកម្មវិធីអប់រំសាធារណៈមួយ ដើម្បីឱ្យគេស្គាល់ និងជៀសវាងគ្រឿងផ្ទុះទាំងឡាយនោះ ។

ខ - ហ្វឹកហ្វឺនអ្នកស្មគ្រចិត្តកម្ពុជា អោយបំផ្លាញចោល គ្រឿងយុទ្ធភណ្ឌដែលមិនទាន់ផ្ទុះទាំងនោះ ។

គ - បង្ហាត់ហ្វឹកហ្វឺនវិជ្ជាខាងការជួយសង្គ្រោះបន្ទាន់ ដល់អ្នកស្ម័គ្រចិត្តកម្ពុជា ។

## មាត្រា ១០

## ការស៊ើបអង្កេតចំពោះការរំលោភទាំងឡាយ

១ - ក្រោយពីការចាប់ផ្ដើមដំណាក់កាលទី ២ នៅពេលបានទទួលពត៌មាន ឬក៏ពាក្យបណ្ដឹង តវ៉ាណាមួយ ពីភាគីណាមួយ ដែលទាក់ទងទៅនឹងករណីមិនគោរព អនុវត្តតាមប្រការណាមួយ នៃឧបសម្ព័ន្ធនេះ ឬក៏ប្រការផ្សេងៗ ដែលពាក់ព័ន្ធ អ៊ុនតាក់ ត្រូវធ្វើការស៊ើបអង្កេតតាមរូបភាពមួយ ដែលខ្លួនយល់ថាសមស្រប ។ នៅពេលដែលការស៊ើបអង្កេតប្រព្រឹត្ត ទៅ ដើម្បីឆ្លើយតបចំពោះបណ្ដឹងតវ៉ារបស់ភាគីណាមួយ ភាគីនោះនឹងត្រូវស្នើសុំអោយផ្ដល់ បុគ្គលិករបស់ខ្លួនជូនដំណើរ អ្នកស៊ើបអង្កេតរបស់ អ៊ុនតាក់ ។ លទ្ធផលនៃការស៊ើបអង្កេតបែបនេះ នឹងត្រូវបញ្ជូនដោយ អ៊ុនតាក់ ទៅអោយ ភាគីដែលប្ដឹងតវ៉ា និង ភាគីដែលត្រូវគេប្ដឹងនោះ ហើយបើចាំបាច់ ទៅអោយអេសអិនស៊ី ។

២ - អ៊ុនតាក់ ក៏នឹងធ្វើការស៊ើបអង្កេត ដោយគំនិតផ្ដើមខ្លួនឯងផ្ទាល់ដែរ ក្នុងករណីផ្សេងៗទៀត នៅពេលដែលខ្លួនមានហេតុផល និងជឿ ឬសង្ស័យថា ការរំលោភលើឧបសម្ព័ន្ធនេះ ឬ ប្រការទាក់ទិនផ្សេងៗទៀតអាចកើតមាន ។

## មាត្រា ១១

## ការដោះលែងឈ្លើយសឹក

ផ្នែកយោធានៃ អ៊ុនតាក់ នឹងជួយឧបត្ថម្ភដល់គណៈកម្មការកាកបាទក្រហម អន្តរជាតិតាមសំណូមពរ ក្នុងការបំពេញភារកិច្ចរបស់អង្គការនេះ ទាក់ទងទៅនឹងការដោះលែងឈ្លើយសឹក ។

# មាត្រា ១២

ការធ្វើមាតុភូមិនិវត្តន៍ និង ការតាំងទីលំនៅ
ជាថ្មីនៃប្រជាជនកម្ពុជា ផ្លាស់ប្តូរទីកន្លែង

ផ្នែកយោធានៃ អ៊ុនតាក់ នឹងជួយឧបត្ថម្ភតាមការចាំបាច់ដល់ការ ធ្វើមាតុភូមិនិវត្តន៍របស់ភៀសខ្លួន និង ជនផ្លាសប្តូរទីកន្លែងកម្ពុជា ដែលអនុវត្តទៅស្របនឹងមាត្រាទី ១៩ និង ២០ នៃកិច្ចព្រមព្រៀងនេះ ជាពិសេសការបោសសំអាតមីន ចេញពីផ្លូវធ្វើមាតុភូមិនិវត្តន៍ និង មណ្ឌលទទួល និង តំបន់តាំងទីលំនៅថ្មី ព្រមទាំងការពារមណ្ឌលទទួល ជនភៀសខ្លួនផង ។

# ឧបសម្ព័ន្ធទី ៣

## ការបោះឆ្នោត

១ - សភាធម្មនុញ្ញដែលមានលើកឡើងនៅក្នុងមាត្រាទី ១២ នៃកិច្ចព្រមព្រៀង ត្រូវមានសមាជិកចំនួន ១២០ នាក់ ។ នៅក្នុងរយៈពេល ៣ ខែ ចាប់ពីពេលបោះឆ្នោតសភាធម្មនុញ្ញ ត្រូវបំពេញបញ្ចប់ភារកិច្ចរបស់ខ្លួន ក្នុងការធ្វើសេចក្តីព្រាង ហើយអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា និងប្រែក្លាយខ្លួនឯងឱ្យទៅជាសភានីតិបញ្ញត្តិមួយ ដែលនឹងត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាថ្មីមួយឡើង ។

២ - ការបោះឆ្នោតដែលមានលើកឡើង នៅក្នុងមាត្រាទី ១២ នៃកិច្ចព្រមព្រៀងត្រូវប្រព្រឹត្តទៅ នៅទូទាំងប្រទេសកម្ពុជា ស្របតាមប្រព័ន្ធតំណាងសមាមាត្រតាមខេត្ត ដោយផ្អែកទៅលើបញ្ជីរាយនាមរបស់បេក្ខជន ដែលស្នើឡើងដោយបណ្តាគណបក្សនយោបាយ ។

៣ - ជនជាតិកម្ពុជាទាំងអស់ រួមទាំងអ្នកដែលនៅពេលកិច្ចព្រមព្រៀងនេះ បានត្រូវចុះហត្ថលេខា គឺជាជនភៀសខ្លួន និង ជាជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ត្រូវមានសិទ្ធិ សេរីភាព និង ឱកាសដូចៗគ្នា ដើម្បីចូលរួមក្នុងដំណើរការបោះឆ្នោត ។

៤ - អ្នកទាំងឡាយណា ដែលមានអាយុគ្រប់ដប់ប្រាំបីឆ្នាំ នៅក្នុងពេលចុះឈ្មោះបោះឆ្នោត ឬ ក៏ទើបតែដល់អាយុ ១៨ ឆ្នាំ នៅក្នុងរយៈពេលនៃការចុះឈ្មោះបោះឆ្នោតហើយ ឬមួយបានកើតនៅក្នុងប្រទេសកម្ពុជា ឬមួយជាកូនរបស់អ្នកដែលបានកើត នៅក្នុងប្រទេសកម្ពុជា នឹងត្រូវមានសិទ្ធិបោះឆ្នោត ក្នុងការបោះឆ្នោត ។

៥ - គេអាចបង្កើតគណបក្សនយោបាយ ដោយអ្នកដែលមានឈ្មោះ បោះឆ្នោតមួយក្រុម មានមនុស្សចំនួន ៥០០០ នាក់ ។ កម្មវិធីនយោបាយរបស់គណបក្ស ត្រូវសមស្របជាមួយគោលការណ៍ និងទិសដៅនៃកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរួមមួយ ។

៦ - ដើម្បីឈរឈ្មោះអោយគេបោះឆ្នោត ជាសមាជិកសភាធម្មនុញ្ញ បេក្ខជនត្រូវបង្ហាញសមាជិកភាព នៃគណបក្សរបស់ខ្លួន ។ គណបក្សនយោបាយ ត្រូវបង្ហាញបញ្ជីរាយនាមបេក្ខជន ដែលឈរឈ្មោះសម្រាប់ការបោះឆ្នោត ក្នុងនាមគណបក្សនោះ ហើយដែលត្រូវជាអ្នកមានសិទ្ធិបោះឆ្នោត ដែលបានចុះឈ្មោះហើយ ។

៧ - គណបក្សនយោបាយ ហើយនិងបេក្ខជន ត្រូវមានឈ្មោះចុះក្នុងបញ្ជី ដើម្បីឈរឈ្មោះបោះឆ្នោត ។ អ៊ុនតាក់ត្រូវបញ្ជាក់ថា គណបក្សនយោបាយ និងបេក្ខជន មានលក្ខណៈវិនិច្ឆ័យត្រឹមត្រូវ ដូចដែលបានកំណត់ ហើយដើម្បីអោយគេអាចចូលរួម ក្នុងការបោះឆ្នោតបាន ។ ការគោរពតាមយ៉ាងខ្ជាប់ខ្ជួន តាមបទបញ្ជាលីលធម៌មួយ ដែលកំណត់ឡើង ដោយអ៊ុនតាក់ ដោយមានការពិគ្រោះយោបល់ ជាមួយនឹងអេសអិនស៊ីផងនេះ ត្រូវធ្វើជាលក្ខណ្ឌមួយ សម្រាប់ការចូលរួមបោះឆ្នោតនេះ ។

៨ - ការបោះឆ្នោត នឹងត្រូវធ្វើដោយសន្លឹកឆ្នោតជាសម្ងាត់ ដោយមានការរៀបចំ សម្រាប់ជួយដល់អ្នកណាដែលពិការ ឬ ក៏ មិនចេះអាន ឬ មិនចេះសរសេរ ។

៩ - សេរីភាពក្នុងការនិយាយស្តី ក្នុងការប្រជុំគ្នា ហើយនិងក្នុងការធ្វើដំណើរ ត្រូវបានគោរពទាំងស្រុង ។ រាល់គណបក្សនយោបាយ ដែលបានចុះឈ្មោះហើយ អាចប្រើប្រាសប្រាស្រ័យទាក់ទង បានយ៉ាងត្រឹមត្រូវ នូវបណ្តាញឃោសនា រួមមានសារពត៌មាន ទូរទស្សន៍ ហើយនិងវិទ្យុផង ។

# ឧបសម្ព័ន្ធទី ៤

## ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា

## ភាគទី ១

### សេចក្តីផ្តើម

១ - ជាភាគមួយនៃដំណោះស្រាយ នយោបាយរួមនោះ ចាំបាច់ត្រូវផ្តល់ជំនួយឧបត្ថម្ភគ្រប់បែបយ៉ាងដល់ ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ក៏ដូចជាដល់បណ្តាប្រទេស ដែលផ្តល់ជម្រកបណ្តោះអាសន្ន និង ប្រទេសជាប្រភពដើមនៃជនភៀសខ្លួន ដើម្បីសម្រួលដល់ការវិលត្រឡប់ ដោយស្ម័គ្រចិត្ត ដោយសន្តិវិធី និង មានរបៀបរៀបរយរបស់ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាគ្រប់រូប ។ គេក៏ត្រូវធានារ៉ាប់រងផងដែរ ថានឹងមិនមានបញ្ហាសេសសល់ណាឡើយ សម្រាប់ប្រទេសដែលផ្តល់ជម្រកបណ្តោះអាសន្ននោះ ។ ប្រទេសជាប្រភពដើមនៃជនភៀសខ្លួន ដោយមានការទទួលខុសត្រូវ ចំពោះប្រជាជនរបស់ខ្លួនផ្ទាល់ ត្រូវទទួលយកការវិលត្រឡប់របស់ពួកគេ នៅពេលណាមានលក្ខណៈ អំណោយផលហើយនោះ ។

## ភាគទី ២

### បណ្តាលក្ខណៈដែលសម្រួលអោយការវិលត្រឡប់នៃ ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែង

២ - ភារកិច្ចកសាងប្រជាជាតិកម្ពុជាឡើងវិញ តម្រូវអោយគេគ្រប់គ្រង ប្រើប្រាសរាល់ធនធាន ខាងកម្លាំងមនុស្ស និង ធម្មជាតិទាំងអស់របស់ប្រទេសនេះ ។ ដើម្បីសម្រេចគោលដៅនេះ ការវិលត្រឡប់ទៅកាន់ទីកន្លែង ដែលជនជាតិកម្ពុជាជ្រើសរើសដោយខ្លួនឯងពេលវិលពីទីជម្រកបណ្តោះអាសន្នរបស់ពួកគេ និង ពីទីកន្លែងដទៃទៀតនៅក្រៅប្រទេសដែលជាដើមកំណើតរបស់ពួកគេនោះ គឺជាការរួមវិភាគទានមួយដ៏សំខាន់ ។

៣ - គេត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីធានាថា លក្ខណៈសម្បត្តិ ដែលបាននាំអោយមាន ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជាមួយចំនួនធំ បានទៅរកទីជំរកនៅបណ្តាប្រទេសដទៃទៀតនោះ មិនកើតមានសារជាថ្មីឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជាខ្លះ ដែលមានបំណងនឹងអាចវិលត្រឡប់ដោយភ្លាមៗខ្លួនឯង ទៅកាន់មាតុភូមិរបស់ពួកគេវិញ ។

៤ - ត្រូវមានការគោរពទាំងស្រុង ចំពោះសិទ្ធិមនុស្ស និង សេរីភាព ជាមូលដ្ឋានរបស់ជនកម្ពុជាគ្រប់រូប រួមទាំងសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន របស់ជនភៀសខ្លួន និង ជនផ្លាសប្តូរទីកន្លែង ដែលបានវិលត្រឡប់ ទៅកាន់មាតុភូមិវិញផងដោយទទួលស្គាល់ដល់សិទ្ធិរបស់ពួកគេ ដើម្បីរស់នៅដោយសន្តិភាព និង សន្តិសុខ ដោយគ្មានការសំឡុតកំហែង ឬបង្ខិតបង្ខំអ្វីទាំងអស់ ។ សិទ្ធិទាំងនោះនឹងរួមមានក្នុងចំណោមសិទ្ធិដទៃទៀត សេរីភាព ក្នុងការធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា សិទ្ធិជ្រើសរើសលំនៅដ្ឋាន និងប្រកបមុខរបរការងារ ហើយនិងសិទ្ធិក្នុងការមានកម្មសិទ្ធិ ។

៥ - សមស្របទៅតាមដំណោះស្រាយនយោបាយរួម គេត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីបង្កើតក្នុងពេលជាមួយគ្នានៅក្នុងប្រទេសកម្ពុជា នូវលក្ខណសម្បត្តិខាងនយោបាយ សេដ្ឋកិច្ច និង សង្គម ដែលសម្រួលដល់ការវិលត្រឡប់ និងការចូលមករស់នៅវិញ ដោយសុខដមរមនានៃជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ។

៦ - ដើម្បីធានាអោយជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា បានចូលរួមក្នុងការបោះឆ្នោត ការធ្វើមាតុភូមិនិវត្តន៍ដោយទ្រង់ទ្រាយធំ ត្រូវចាប់ផ្តើម និង បញ្ចប់អោយបានឆាប់រហ័សបំផុត តាមដែលអាចធ្វើបានដោយគិតគូរ ទៅដល់កត្តានយោបាយ មនុស្សធម៌ ភស្តុភារ ដឹកជញ្ជូន បច្ចេកទេស សង្គមកិច្ច ដែលពាក់ព័ន្ធ និង ដោយរួមសហប្រតិបត្តិការ ជាមួយនឹងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។

៧ - ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយការសម្រេចចិត្តរបស់ពួកគេ ត្រូវឈរទាំងស្រុងលើការក្តាប់បាន នូវសភាពការណ៍ជាក់ស្តែង ។ ការជ្រើសរើសទីដៅនៅខាងក្នុងប្រទេសកម្ពុជា គប្បីជាសិទ្ធិជ្រើសរើសរបស់បុគ្គលម្នាក់ៗ ។ គេត្រូវរក្សាការឯកភាព របស់គ្រួសារនិមួយៗ ។

## ភាគទី ៣

## កត្តាប្រតិបត្តិការ

៨ - ស្របនឹងការគោរពចពោះបណ្តា គោលការណ៍នៃអធិបតេយ្យភាពជាតិ ក្នុងប្រទេសដែលបានផ្តល់ជំរកបណ្តោះអាសន្ន និង ប្រទេសជាប្រភពដើម ហើយដោយមានសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយប្រទេស ដែលបានផ្តល់ជម្រកបណ្តោះអាសន្ន និង ប្រទេសជាប្រភបដើមផង គេត្រូវធានាអោយឧត្តមស្នងការ សហប្រជាជាតិសម្រាប់ជនភៀសខ្លួន គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ព្រមទាំងអង្គការអន្តរជាតិដទៃទៀត ដែលពាក់ព័ន្ធបានជួបប្រាស្រ័យយ៉ាងពេញលេញ ជាមួយជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាទាំងអស់ ដើម្បីអោយបណ្តាភ្នាក់ងារទាំងនោះ ធ្វើការ

ជម្រៀនប្រជាជន ស្វែងរកញាតិគ្រួសារ ផ្តល់ជំនួយសង្គ្រោះផ្នែកពេទ្យ ចែកចាយស្បៀងអាហារ ព្រមទាំងធ្វើសកម្មភាពផ្សេងៗទៀត ដែលចាំបាច់បំផុតដល់ការបំពេញភារកិច្ច និងការទទួលខុសត្រូវ ខាងផ្នែកប្រតិបត្តិការរបស់ពួកគេ ។ គេត្រូវអនុញ្ញាតអោយមានការជួបប្រាស្រ័យទាក់ទងបែបនេះផងដែរ នៅប្រទេសកម្ពុជា ដើម្បីអោយបណ្តាអង្គការ អន្តរជាតិដែលពាក់ព័ន្ធអាចអនុវត្តភារកិច្ចទទួលខុសត្រូវជាទំលាប់របស់គេ ខាងការតាមដានក៏ដូចខាងប្រតិបត្តិការ ។

៩ - នៅក្នុងក្របខ័ណ្ឌនៃដំណោះស្រាយនយោបាយរួម បណ្តាហត្ថលេខីធ្វើការកត់សម្គាល់ ដោយសេចក្តីពេញចិត្តថា លោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ បានប្រគល់អោយឧត្តមស្នងការដ្ឋាន អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន UNHCR នូវតួនាទីដឹកនាំ និង សម្របសម្រួលក្នុងបណ្តា អង្គការអន្តររដ្ឋាភិបាល ដែលជួយឧបត្ថម្ភដល់ការធ្វើមាតុភូមិនិវត្តន៍ និង ផ្តល់ជំនួយសង្គ្រោះដល់ជនភៀសខ្លួន និង ជនផ្លាស់ទីកន្លែងកម្ពុជា ។ បណ្តាហត្ថលេខីរំពឹងថា អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត នឹងធ្វើការសម្របសម្រួលការងាររបស់ខ្លួន អោយបានច្រើនបំផុតជាមួយ UNHCR សម្រាប់ជនភៀសខ្លួន និង ជនផ្លាស់ទីកន្លែងកម្ពុជា ។

១០ - ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ រដ្ឋាភិបាលនៃបណ្តាប្រទេសដែលជនភៀសខ្លួន និង ជនផ្លាស់ទីកន្លែងកម្ពុជា បានជ្រកកោណបណ្តោះអាសន្ន ព្រមទាំងបណ្តាប្រទេស ដែលរួមចំណែកដល់កិច្ចប្រឹងប្រែង ក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការចូលមករស់នៅវិញ នឹងមានបំណងតាមដានយ៉ាងជិតស្និទ្ធ ហើយជួយសម្រួលដល់ ការធ្វើមាតុភូមិនិវត្តន៍ នៃអ្នកដែលវិលត្រឡប់វិញនោះ ។ អង្គការចំពោះកិច្ចដើម្បីពិគ្រោះយោបល់ ADHOC មួយត្រូវបង្កើតឡើង សម្រាប់រយៈពេលមួយជាកំណត់ ដើម្បីគោលដៅនេះ ។ ឧត្តមស្នងការអង្គការសហប្រជាជាតិ សម្រាប់ជនភៀសខ្លួន គណៈកម្មការកាកបាទក្រហមអន្តរជាតិ ព្រមទាំងអង្គការអន្តរជាតិ ដែលសមស្របដទៃទៀត ក៏ដូចជាអ៊ុនតាក់ដែរ នឹងត្រូវអញ្ជើញអោយចូលរួម ជាសមាជិកពេញសិទ្ធិ ។

១១ - ជំនួយឧបត្ថម្ភសម្រាប់រយៈពេលខ្លី ដល់ការធ្វើមាតុភូមិនិវត្តន៍ ហើយដោយមានការតាមដាន ដ៏សមស្របផងនោះ ត្រូវផ្តល់អោយដោយមិនលំអៀង ដើម្បីជួយអោយបណ្តាគ្រួសារ និង បុគ្គលដែលវិលត្រឡប់មកកម្ពុជាវិញ អាចកសាងជីវភាពរស់នៅ របស់គេបានដោយសុខដុមរមនា នៅក្នុងសង្គមរបស់ខ្លួន ។ វិធានការជាបណ្តោះអាសន្នទាំងនេះ នឹងត្រូវកាត់បន្ថយជាបណ្តើរៗ ហើយនិងជំនួសវិញ សម្រាប់រយៈពាលវែងដោយកម្មវិធីកសាងឡើងវិញ ។

១២ - អ្នកដែលទទួលខុសត្រូវចំពោះការចាត់ចែង ហើយនិងពិនិត្យមើលប្រតិបត្តិការ នៃការធ្វើមាតុភូមិនិវត្តន៍ ចាំបាច់ត្រូវធានាថាលក្ខណៈសម្បត្តិសន្តិសុខ សម្រាប់ការធ្វើដំណើររបស់ជនភៀសខ្លួន ហើយនិងជនផ្លាស់ទីកន្លែងត្រូវបានរៀបចំហើយ ។ នៅក្នុងន័យនេះ ជាការចាំបាច់ណាស់ ដែលត្រូវកំណត់អោយហើយ ស្រេចនូវចំណុចឆ្លងកាត់ព្រំដែន និង ផ្លូវធ្វើដំណើរដ៏សមស្រប ដោយត្រូវបោសសំអាតមីន និង គ្រោះថ្នាក់ផ្សេងៗ ។

១៣ - សហគមន៍អន្តរជាតិគួររួមវិភាគទាន ដោយសប្បុរសដល់សេចក្តីត្រូវការ ផ្នែកហិរញ្ញវត្ថុសម្រាប់កិច្ចប្រតិប្តិការ ធ្វើមាតុភូមិនិវត្តន៍ ។

# ឧបសម្ព័ន្ធទី ៥

## បណ្ដាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មី
## មួយរបស់កម្ពុជា

១ - រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេស ។ គេអាចធ្វើការកែប្រែរដ្ឋធម្មនុញ្ញនេះបាន លុះត្រាតែមានរបៀបរបប ចាត់តាំងមួយទាក់ទងដល់ការយល់ព្រម ពីអង្គការនីតិបញ្ញត្តិ ការធ្វើប្រជាមតិ ឬ ក៏ដោយវិធីទាំងពីរនេះតែម្ដង ។

២ - ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារអោយមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញត្រូវរួមមាន សេចក្ដីថ្លែងការណ៍មួយ អំពីសិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមានសិទ្ធិ ក្នុងការមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នា និងបង្កើតសមាគម រួមមានគណបក្សនយោបាយ និង សហជីព ដំណើរការតុលាការត្រឹមត្រូវ និង ភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំអោយមាន ការដកហូតកម្មសិទ្ធិដោយវិធីផ្ដាច់ការ ឬ ការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជម្ងឺចិត្ត ដ៏ត្រឹមត្រូវ និង សេរីភាព ដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿសាសនា ឬភេទឡើយ ។ រដ្ឋធម្មនុញ្ញត្រូវហាមឃាត់ នូវការអនុវត្តច្បាប់ឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល ។ សេចក្ដីប្រកាស ត្រូវសមស្របទៅនឹងប្រការទាំងឡាយ នៃសេចក្ដីប្រកាសជាសាកល អំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ដែលពាក់ព័ន្ធ ។ បុគ្គលដែលត្រូវរំលោភបំពាន មានសិទ្ធិប្ដឹងទៅតុលាការ ដើម្បីកាត់សេចក្ដី និង ធ្វើអោយគេគោរពសិទ្ធិទាំងអស់នេះ ។

៣ - រដ្ឋធម្មនុញ្ញត្រូវ ប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជា ជារដ្ឋអធិបតេយ្យ ឯករាជ្យ និង អព្យាក្រិតមួយ និង អំពីឯកភាពជាតិរបស់ប្រជាជនកម្ពុជា ។

៤ - រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរី ដោយឈរលើមូលដ្ឋាន ពហុបក្ស ។ រដ្ឋធម្មនុញ្ញត្រូវកំណត់អោយ មានការបោះឆ្នោតដ៏ត្រឹមត្រូវ និង តាមកាលវេលា ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាត សិទ្ធិសម្រាប់បោះឆ្នោត និង ឈរឈ្មោះអោយគេបោះឆ្នោត តាមរបៀបបោះឆ្នោតដោយសាកល និង ស្មើភាព ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតអោយមានការបោះឆ្នោត ដោយសម្ងាត់ ដោយតម្រូវអោយទម្រង់បែបបទ នៃការបោះឆ្នោត ត្រូវផ្ដល់ឱកាសគ្រប់គ្រាន់ និង សមរម្យ ដើម្បីរៀបចំ និង ចូលរួមក្នុងដំណើរការបោះឆ្នោត ។

៥ - ត្រូវបង្កើតអង្គការតុលាការមួយឯករាជ្យ ដែលត្រូវមានអំណាចដាក់អោយ អនុវត្តនូវបណ្ដាសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

៦ - រដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសំឡេងភាគច្រើនពីរភាគបី នៃសមាជិករបស់សភាធម្មនុញ្ញ ។

# II

# កិច្ចព្រមព្រៀងទាក់ទិននៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិកម្ពុជា

អូស្ត្រាលី ប្រ៊ុយណេដារូសាឡាម កម្ពុជា កាណាដា សាធារណរដ្ឋ ប្រជាមានិតចិន សាធារណរដ្ឋបារាំង សាធរណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធរណរដ្ឋហ្វីលិពីន សាធារណរដ្ឋសឹង្ហបូរី រាជាណាចក្រថៃឡង់ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ចក្រភពអង់គ្លេស និង អៀរឡង់ខាងជើង សហរដ្ឋអាមេរិក សាធារណរដ្ឋសង្គមនិយមវៀតណាម និង សាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ។

ដោយមានវត្តមានរបស់លោក អគ្គលេខាធិការ អង្គការសហប្រជាជាតិ ។

*ដោយជឿជាក់ថា* ដំណោះស្រាយនយោបាយរួមមួយសម្រាប់កម្ពុជា មានសារសំខាន់ សម្រាប់គោលដៅយូរអង្វែងនៃការរក្សាសន្តិភាពនិងសន្តិសុខនៅអាស៊ីអាគ្នេយ៍ ។

*ដោយរំលឹកឡើងវិញ* នូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និង បទបញ្ញត្តិ នៃច្បាប់អន្តរជាតិដទៃទៀត ។

*ដោយចាត់ទុកថា* ការគោរពដ៏ពេញលេញនូវ គោលការណ៍មិនជ្រៀតជ្រែក និង មិនអន្តរាគមន៍ចូលកិច្ចការផ្ទៃក្នុង និង កិច្ចការក្រៅប្រទេស របស់បណ្តារដ្ឋ គឺមានសារសំខាន់ ដ៏ធំបំផុតសម្រាប់ថែរក្សាសន្តិភាព និង សន្តិសុខអន្តរជាតិ ។

*ដោយអះអាងឡើងវិញ* អំពីសិទ្ធិមិនអាចបាត់បង់បានរបស់បណ្តារដ្ឋដើម្បីសម្រេចដោយសេរី នូវប្រព័ន្ធនយោបាយ សេដ្ឋកិច្ច វប្បធម៌ និង សង្គមរបស់ខ្លួនស្របតាមគោលបំណងរបស់ប្រជាជនខ្លួន ដោយគ្មានការជ្រៀតជ្រែក វិទ្ធង្សនា កាបង្ខិតបង្ខំ ឬ គម្រាមកំហែងខាងក្រៅ ទៅតាមរូបភាពបែបណាមួយក៏ដោយ ។

ដោយចង់ជំរុញ ការគោរព និង អនុវត្តតាមសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ ដែលទាក់ទិនដទៃៗទៀត ។

*បានព្រមព្រៀងដូចតទៅ ៖*

# មាត្រាទី ១

១ - កម្ពុជា តាមរយៈឯកសារនេះ សន្យាយ៉ាងឱឡារិកថា នឹងថែរក្សា និង ការពារអធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ខ្លួន ។ អព្យាក្រឹតភាពអចិន្ត្រៃយ៍របស់កម្ពុជា នឹងត្រូវប្រកាសហើយ និងចារិកទុកនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដែលនឹងត្រូវអនុម័តក្រោយពីការបោះឆ្នោត ដោយសេរី និង ត្រឹមត្រូវ ។

២ - ដើម្បីសម្រេចទិសដៅនេះ កម្ពុជាសន្យាថា :

ក - ចៀសវាងអំពើណាមួយ ដេលអាចនាំអោយប៉ះពាល់ដល់ អធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិន អាចរំលោភបាននៃដេនដី របស់រដ្ឋដទៃ ។

ខ - ចៀសវាងចូលរួមក្នុងសម្ព័ន្ធភាពយោធា ឬ បណ្តាកិច្ចព្រមព្រៀងយោធាណាមួយ នឹង រដ្ឋដទៃៗទៀត ដែលមិន ស្របតាមអព្យាក្រឹតភាពរបស់ខ្លួន តែប្រការនេះមិនមានប៉ះពាល់ដល់សិទ្ធិរបស់កម្ពុជា ក្នុងការទទួលយកសម្ភារៈយោធា អាវុធ គ្រាប់រំសេវ និង ជំនួយចាំបាច់ ដែលអាចអោយកម្ពុជាអនុវត្តសិទ្ធិដ៏ពេញលេញរបស់ខ្លួន ដើម្បីស្វ័យការពារ និង ដើម្បីថែរក្សាច្បាប់ និង សណ្តាប់ធ្នាប់ ។

គ - ចៀសវាងជ្រៀតជ្រែក ចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃៗទៀត ដោយផ្ទាល់ ឬដោយប្រយោល ទោះតាមរូបភាព ណាក៏ដោយ ។

ឃ - បញ្ចប់សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយ ដែលមិនសមស្របទៅនឹង អធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាច រំលោភបាននៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ខ្លួន ។

ង - ចៀសវាងគមរាមកំហែង ឬ ប្រើកំលាំង ប្រឆាំងនឹងបូរណភាពដែនដី ឬ ឯករាជ្យនយោបាយនៃរដ្ឋណាមួយ ឬ ដោយឥរិយាបថណាមួយ ដែលមិនស្របនឹងគោលបំណង របស់អង្គការសហប្រជាជាតិ ។

ច - ដោះស្រាយរាល់ជម្លោះ ជាមួយនឹងរដ្ឋដទៃៗទៀត ដោយសន្តិវិធី ។

ឆ - ចៀសវាងប្រើដែនដីរបស់ខ្លួន ឬ ដែនដីរបស់រដ្ឋដទៃៗទៀត ដើម្បីធ្វើអោយប៉ះពាល់ដល់ អធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដីរបស់រដ្ឋដទៃៗទៀត ។

ជ - ចៀសវាងអនុញ្ញាតអោយបញ្ចូល ឬ ដាក់ទីតាំង កងកំលាំងបរទេស រួមទាំងបុគ្គលិកយោធា ទោះក្នុងរូបភាព ណាក៏ដោយនៅកម្ពុជា និង ទបស្កាត់ការបង្កើត ឬ រក្សាទុកមូលដ្ឋានយោធាបរទេស ចំណុចបង្អែក ឬ ទីកន្លែងមធ្យោបាយនៅកម្ពុជាឡើយ លើកលែងតែមានការអនុញ្ញាត របស់អង្គការសហប្រជាជាតិ សម្រាប់

អនុវត្តនូវដំណោះស្រាយយោធារួមមួយ ។

## មាត្រាទី ២

១ - ភាគីនានាក្នុងកិច្ចព្រមព្រៀងនេះ តាមរយៈនេះសន្យាយ៉ាងឱឡារិកថា ទទួលស្គាល់ និង គោរពគ្រប់បែបយ៉ាងទាំងអស់ ដល់អធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបានដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិកម្ពុជា ។

២ - ដើម្បីសម្រេចទិសដៅនេះ ភាគីទាំងនេះសន្យាថា :

ក - ចៀសវាងចូលរួមក្នុងបក្សសម្ព័ន្ធយោធាណាមួយ ឬក៏ក្នុងកិច្ចព្រមព្រៀងយោធាផ្សេងណា ជាមួយកម្ពុជាដែលមិនសមស្រប នឹងអព្យាក្រឹតភាពរបស់កម្ពុជា តែប្រការទាំងនេះមិនធ្វើអោយប៉ះពាល់ដល់ សិទ្ធិកម្ពុជាក្នុងការទទួលសម្ភារៈយោធា អាវុធ គ្រាប់រំសេវ និងជំនួយដេលចាំបាច់ ដើម្បីអោយកម្ពុជា ប្រើប្រាសនូវសិទ្ធិដ៏ពេញលេញរបស់ខ្លួន សម្រាប់ការការពារខ្លួន និងដើម្បីរក្សាច្បាប់ និងសណ្តាប់ធ្នាប់ ។

ខ - ចៀសវាងជ្រៀតជ្រែតចូលកិច្ចការផ្ទៃក្នុងកម្ពុជា ទោះក្នុងរូបភាពណាមួយក៏ដោយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។

គ - ចៀសវាងគំរាមកំហែង ឬ ក៏ប្រើប្រាសកំលាំងប្រឆាំង នឹងបូរណភាពដែនដី ឬ ក៏ឯករាជ្យខាងនយោបាយរបស់កម្ពុជា ក្នុងរូបភាពណាមួយ ដែលមិនសមស្របនឹងគោលបំណង របស់អង្គការសហប្រជាជាតិ ។

ឃ - ដោះស្រាយរាល់ជម្លោះជាមួយកម្ពុជាដោយសន្តិវិធី ។

ង - ចៀសវាងប្រើប្រាសទឹកដីរបស់ខ្លួន ឬក៏ទឹកដីរបស់រដ្ឋដទៃទៀត ដើម្បីធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដីអព្យាក្រិត និង ឯកភាពជាតិរបស់កម្ពុជា ។

ច - ចៀសវាងប្រើប្រាសទឹកដីកម្ពុជា ដើម្បីធ្វើអោយប៉ះពាល់ដល់ អធិបតេយ្យភាព ឯករាជ្យ និង បូរណភាព និង ភាពមិនអាចរលោភបាន នៃដេនដី របស់រដ្ឋដទៃទៀត ។

ឆ - ចៀសវាងបញ្ចូល ឬ តាំងមូលដ្ឋានកងកម្លាំងបរទេស រួមទាំងបុគ្គលិកយោធានៅក្នុងកម្ពុជា ទោះក្នុងរូបភាពណាក៏ដោយ និង ចៀសវាង បង្កើត ឬ ក៏រក្សាទុកនូវ មូលដ្ឋានយោធា ចំណុចបង្អែក ឬ ទីតាំងមធ្យោបាយនៅក្នុងកម្ពុជា លើកលែងតែមានការអនុញ្ញាត ពីអង្គការសហប្រជាជាតិ សម្រាប់ការអនុវត្តដំណោះស្រាយនយោបាយរួមមួយ ។

## មាត្រាទី ៣

១ - មនុស្សទាំងអស់នៅកម្ពុជាត្រូវមានសិទ្ធិ និង សេរីភាព ដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ ជាសាកលស្តីពីសិទ្ធិមនុស្ស និង ច្បាប់អន្តរជាតិ ទាក់ទិននិងសិទ្ធិមនុស្សដទៃទៀត ។

២ - ក្នុងគោលដៅនេះ

ក - កម្ពុជាសន្យាថាៈ

- ធានាគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស ហើយនិងសេរីភាព ជាមូលដ្ឋាននៅកម្ពុជា ។

- គាំទ្រសិទ្ធិពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីធ្វើសកម្មភាព ដែលជំរុញ និង ការការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ។

- ចាត់វិធានការណ៍ ដ៏មានប្រសិទ្ធភាព ដើម្បីធានាកុំអោយនយោបាយ និង អំពើប្រព្រឹត្តនៅក្នុងអតីតកាលវិលត្រឡប់មកវិញជាដាច់ខាត ។

- ចូលរួមក្នុងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលទាក់ទិន ។

ខ - ភាគីឯទៀត ដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ សន្យាបង្កើន និង លើកទឹកចិត្តដល់ការគោរព និង អនុវត្តតាមសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាននៅកម្ពុជា ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ដើម្បីជាតិពិសេសទប់ស្កាត់កុំអោយមានការរំលោភសិទ្ធិមនុស្សឡើងវិញ ។

៣ - គណៈកម្មការអំពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ត្រូវបន្តតាមដានដោយដិតដល់ស្ថានការណ៍ សិទ្ធិមនុស្សនៅកម្ពុជា រួមទាំងក្នុងករណីចាំបាច់ ចាត់តាំងអ្នករាយការណ៍ពិសេសម្នាក់ ដែលត្រូវការរាយការណ៍ អំពីលទ្ធផលនៃការរកឃើញរបស់ខ្លួនជារៀងរាល់ឆ្នាំ ជូនទៅគណៈកម្មការ និង ទៅមហាសន្និបាតអង្គការសហប្រជាជាតិ ។

## មាត្រាទី ៤

ភាគីដែលចុះកិច្ចព្រមព្រៀងនេះ អំពាវនាវដល់រដ្ឋដទៃទៀត អោយទទួលស្គាល់ និងគោរពគ្រប់បែបយ៉ាង ដល់អធិបតេយ្យភាព ឯការាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រិតភាព និង ឯកភាពជាតិរបស់កម្ពុជា ហើយជៀសវាងធ្វើអំពើដែលមិនសមស្របនិងគោលកាណ៍ទាំងនោះ ឬ ដែលមិនស្របទៅ នឹងប្រការដទៃទៀត នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី ៥

១ - ក្នុងករណីមានការរំលោភ ឬ ការគំរាមកំហែង រំលោភលើអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឬ ឯកភាពជាតិនៃកម្ពុជា ឬលើការប្ដេជ្ញាអនុវត្តដទៃទៀតណាមួយ ក្នុងកិច្ចព្រមព្រៀងនេះ បណ្ដាភាគីក្នុងកិច្ចព្រមព្រៀងនេះ ធ្វើការពិគ្រោះជាបន្ទាន់ ដើម្បីអនុម័តរាល់វិធានការណ៍សមស្រប ដើម្បីធានាការគោរពដល់ការ ប្ដេជ្ញាចិត្តទាំងនោះ និង ដោះស្រាយរាល់ការរំលោភទាំងនោះ តាមមធ្យោបាយសន្តិវិធី ។

២ - វិធានការបែបនេះ ក្នុងចំណោមវិធានការផ្សេងទៀត អាចរួមមាន ការរាយការណ៍ទៅក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ឬ ប្រើប្រាសមធ្យោបាយដំណោះស្រាយ នូវទំនាស់ដោយសន្តិវិធី យោងទៅតាមមាត្រា ៣៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

៣ - បណ្ដាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក៏អាចសុំការឧបត្ថម្ភពីសហប្រធាន នៃសន្និសិទប៉ារីសស្ដីពីកម្ពុជាដែរ ។

៤ - ក្នុងករណីមានការរំលោភយ៉ាងធ្ងន់ធ្ងរ លើសិទ្ធិមនុស្សនៅកម្ពុជា ភាគីក្នុងកិច្ចព្រមព្រៀង ត្រូវស្នើដល់អង្គការមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ អោយចាត់វិធានការដទៃទៀត ដែលសមស្រប ដើម្បីទប់ស្កាត់ និង លិបបំបាត់ការរំលោភបែបនេះ ដោយស្របតាមច្បាប់អន្តរជាតិដែលទាក់ទិន ។

## មាត្រទី ៦

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាន នៅពេលចុះហត្ថលេខា ។

## មាត្រាទី ៧

កិច្ចព្រមព្រៀងនេះ ត្រូវទុកចំហរសម្រាប់រដ្ឋទាំងអស់ចូលរួម ។ ពាក្យសុំចូលផ្លូវការ ត្រូវតំកល់ទុកនៅនឹងរដ្ឋាភិបាលសាធារណរដ្ឋបារាំង និងសាធារណរដ្ឋឥណ្ឌូណេស៊ី ។សម្រាប់រដ្ឋនិមួយៗ ដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ ពាក្យសុំចូលនោះ ត្រូវចូលជាធរមាននៅថ្ងៃដំកល់ទុកពាក្យសុំចូលរួមរបស់ខ្លួន ។

## មាត្រាទី ៨

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលមានជាភាសាចិន - អង់គ្លេស - បារាំង - ខ្មែរ និង រុស្ស៊ី មានតម្លៃដូចគ្នា ត្រូវដាក់តម្កល់ទុកនៅរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និង សាធារណរដ្ឋឥណ្ឌូណេស៊ី ដែលនឹងបញ្ជូននូវច្បាប់ចំឡងដែលបានបញ្ជាក់ត្រឹមត្រូវហើយ ទៅអោយរដ្ឋាភិបាលនៃរដ្ឋដទៃៗ ដែលចូលរួមក្នុងសន្និសិទប៉ារីសស្ដីពីកម្ពុជា និងជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ដើម្បីជាសក្ខីភាព បណ្ដាប្រតិភូពេញសមត្ថកិច្ច ដូចមាននាមខាងក្រោម ដែលទទួលសិទ្ធិត្រឹមត្រូវហើយនោះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

*ធ្វើនៅក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ១៩៩១*

# III

# សេចក្តីថ្លែងការណ៍ ស្តីពីការស្តារ និង ការកសាង ប្រទេសកម្ពុជាឡើងវិញ

១ - ទិសដៅជាបឋម នៃការកសាងប្រទេសកម្ពុជាឡើងវិញ គឺការរីកចម្រើននៃប្រជាជាតិ និងប្រជាជនកម្ពុជា ដោយគ្មានការប្រកាន់រើសអើង ឬ ការធ្វើអោយខូចប្រយោជន៍ ហើយដោយគោរពយ៉ាងពេញលេញ ដល់សិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋានសម្រាប់ជនគ្រប់ៗរូប ។ ដើម្បីសម្រេចអោយបានគោលដៅនេះ គឺត្រូវទាមទារអនុវត្តដ៏ពេញលេញ នូវដំណោះស្រាយនយោបាយរួមមួយ ។

២ - ការទទួលខុសត្រូវជាសំខាន់ ក្នុងការសម្រេចអំពីសេចក្តីត្រូវការ និង គំរោងផែនការណ៍ទាំងឡាយ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ត្រូវស្ថិតនៅលើប្រជាជន និង រដ្ឋាភិបាលកម្ពុជាដែលត្រូវបង្កើតឡើងតាមរយៈ ការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ។ មិនត្រូវមានការប៉ុនប៉ង ពីសំណាក់ប្រភពខាងក្រៅណាមួយ ឬ រារាំងទាយក (អ្នកផ្តល់អំណោយ) ទាំងឡាយ ក្នុងការចូលរួមចំណែកដល់ការកសាង ប្រទេសកម្ពុជាឡើងវិញនោះឡើយ ។

៣ - ជំនួយឧបត្ថម្ភជាលក្ខណៈអន្តរជាតិ ជាលក្ខណៈតំបន់ និងជាលក្ខណៈ ទ្វេភាគីដល់ប្រទេសកម្ពុជា គប្បីត្រូវបានសម្របសម្រួលជាអតិបរមា តាមការដែលអាចធ្វើទៅបាន ដើម្បីបំពេញ ឬ បន្ថែម ទៅលើធនធានក្នុងប្រទេស ហើយនិងត្រូវបានផ្តល់អោយ ដោយឥតលំអៀង និង ដោយគិតគូរយ៉ាងពេញលេញ ដល់អធិបតេយ្យភាព អាទិភាព មធ្យោបាយទាំងឡាយនៃស្ថាប័ននានា ហើយនឹងសមត្ថភាពស្រូបយកជំនួយ របស់ប្រទេសកម្ពុជា ។

៤ - នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រឹងប្រែងកសាងប្រទេសឡើងវិញនេះ ជំនួយសេដ្ឋកិច្ចត្រូវតែបំរើផលប្រយោជន៍ គ្រប់តំបន់នៃប្រទេសកម្ពុជា ជាពិសេសតំបន់ដែលចាញ់ប្រៀបជាងគេ ហើយត្រូវតែបានទៅ ដល់គ្រប់ស្រទាប់នៃសង្គម ។

៥ - ការអនុវត្តនូវការខំប្រឹងប្រែងផ្តល់ជំនួយជាអន្តរជាតិ ត្រូវធ្វើឡើងជាកំណត់នៅក្នុងរយៈពេលមួយ ដែលទទួលស្គាល់ដោយជាក់ស្តែង នូវភាពចាំបាច់ខាងនយោបាយ និង បច្ចេកទេស ។ ការអនុវត្តតម្រូវផងដែរ អោយមានសហប្រតិបត្តិការដ៏សំខាន់មួយ រវាងអានាគតរដ្ឋាភិបាលកម្ពុជា នឹងអ្នកចូលរួមវិភាគទាន ជាទ្វេភាគីក្នុងតំបន់ និង អន្តរជាតិ ។

៦ - ប្រព័ន្ធសហប្រជាជាតិ ត្រូវមានតួនាទីដ៏សំខាន់មួយក្នុងការស្តារ និង កសាងឡើងវិញ ។ ការចាប់ផ្តើមលើកផែនការណ៍កសាងឡើងវិញ និង ការអំពាវនាវជាអន្តរជាតិដើម្បីរកវិភាគទាន ត្រូវប្រព្រឹត្តទៅនៅពេលដ៏សមស្រប ដើម្បីធានានូវជោគជ័យរបស់ខ្លួន ។

៧ - គេមិនអាចផ្តួចផ្តើមកម្មវិធីដ៏មានប្រសិទ្ធិភាព ស្តីពីការកសាងជាតិឡើងវិញបានទេ បើគ្មានការវាយតម្លៃលំអិតអំពីភោគទ្រព្យខាងកម្លាំងមនុស្ស ខាងធម្មជាតិ និងខាងសេដ្ឋកិច្ចផ្សេងៗទៀតនោះ ។ ជាការចាំបាច់ ត្រូវធ្វើបញ្ជីជម្រឿនប្រជាជនពិនិត្យរក

មើលអំពីទិដ្ឋភាពផ្នែកខាងការអភិវឌ្ឍ និង ការកំណត់អោយបានច្បាស់អំពីធនធាន ដែលមាននៅក្នុងនិងក្រៅប្រទេស។

ដើម្បីសម្រេចគោលបំណងនេះ ត្រូវមានគម្រោងបញ្ជូនទៅកាន់កម្ពុជា នូវបេសកម្មស្វែងយល់ការពិត របស់ប្រព័ន្ធអង្គការ សហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងទីភ្នាក់ងារដទៃទៀត ដោយមានការយល់ព្រមពី រដ្ឋាភិបាលកម្ពុជាអនាគត ។

៨ - អាស្រ័យដោយគេសម្រេចបានដំណោះស្រាយ នៃនយោបាយរួមនោះ នាពេលនេះគេអាចធ្វើ ហើយគួរតែធ្វើនូវ ការផ្តួចផ្តើមដំណើរការស្តារឡើងវិញ សំដៅដោះស្រាយសេចក្តីត្រូវការបន្ទាន់ និងកសាងលក្ខណសម្បត្តិមូលដ្ឋាន សម្រាប់ការរៀបចំនូវ ផែនការកសាងឡើងវិញ ដែលមានរយៈពេលមធ្យម និងរយៈពេលវែង ។

៩ - សម្រាប់ដំណាក់កាល នៃការស្តារឡើងវិញនេះ គេស្នើអោយអគ្គលេខាធិការ អង្គការសហប្រជាជាតិ សម្របសម្រួលកម្មវិធីដឹកនាំដោយមនុស្សម្នាក់ ដែលត្រូវបានតែងតាំងឡើង សម្រាប់គោលបំណងនេះ ។

១០ - នៅក្នុងដំណាក់កាលស្តារឡើងវិញនេះ ត្រូវយកចិត្តដាក់ ជាពិសេស ទៅលើការផ្គត់ផ្គង់ស្បៀង សុខភាព ទីលំនៅ ការហ្វឹកហ្វឺន ការអប់រំ ប្រព័ន្ធគមនាគមន៍ និង ការស្តារឡើងវិញនូវ ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និង មធ្យោបាយសម្ភារៈប្រើប្រាសជាសាធារណៈ ដែលមានស្រាប់របស់កម្ពុជា ។

១១ - ការអនុវត្តផែនការអភិវឌ្ឍន៍ ជាអន្តរជាតិសម្រាប់រយៈពេលវែង ស្តីពីការស្តារឡើងវិញ ត្រូវរង់ចាំដល់ការបង្កើតរដ្ឋាភិបាលមួយ បន្ទាប់ពីការបោះឆ្នោត និងការសម្រេចចិត្ត និង ការអនុម័តនូវនយោបាយ និង អាទិភាពផ្ទាល់របស់ខ្លួន ។

១២ - ដំណាក់កាលនៃការកសាងឡើងវិញនេះ ត្រូវជំរុញលើកកំពស់ស្មារតី រកស៊ីធ្វើសហគ្រាសរបស់កម្ពុជា ហើយប្រើប្រាសវិស័យឯកជន ក្នុងចំណោមវិស័យនានាជាច្រើនទៀត ដើម្បីជួយជំរុញការរីកចម្រើនសេដ្ឋកិច្ច ដោយកម្លាំងខ្លួនផ្ទាល់ ។ ដំណាក់កាលនេះ ក៏ត្រូវទទួលផលប្រយោជន៍ ពីតំបន់ផងដែរ ដែលក្នុងនោះមានការពាក់ព័ន្ធ ដល់ស្ថាប័ននានាដូចជាគណៈកម្មការសេដ្ឋកិច្ច - សង្គមកិច្ច សម្រាប់ អាស៊ីប៉ាស៊ីហ្វិក “ESCAP” និងគណៈកម្មាធិការទន្លេមេគង្គជាដើម ហើយពីបណ្តារដ្ឋាភិបាលនៅក្នុងតំបន់ និង ពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ។

១៣ - ដើម្បីបានស៊ីចង្វាក់គ្នា និង តាមដានការធ្វើវិភាគទាន ដែលត្រូវផ្តល់អោយដោយសហគមន៍អន្តរជាតិ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ក្រោយការបង្កើតរដ្ឋាភិបាលមួយ បន្ទាប់ពីការបោះឆ្នោត គេត្រូវបង្កើតស្ថាប័ន ពិគ្រោះយោបល់មួយ ហៅថាគណៈកម្មការអន្តរជាតិ ស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ “ICORC” នៅពេលវេលាមួយសមស្រប និង បើកចំហរចំពោះអ្នកធ្វើអំណោយ និងភាគីផ្សេងទៀតដែលទាក់ទិន ។ គេស្នើរលោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ អោយធ្វើការរៀបចំពិសេសសម្រាប់អោយ ប្រព័ន្ធអង្គការសហប្រជាជាតិ គាំទ្រគណៈកម្មាធិការអន្តរជាតិស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ “ICORC” ក្នុងការធ្វើការងាររបស់ខ្លួន ដូចជាធ្វើអោយមានការផ្ទេរ ដោយគ្មានការរអាក់រអួល ពីដំណាក់កាលស្តារឡើងវិញ ទៅដំណាក់កាលកសាងឡើងវិញ ។

# កិច្ចព្រមព្រៀងចុងក្រោយនៃសន្និសិទ ប៉ារីសស្តីពីកម្ពុជា

១ - សន្និសិទទីក្រុងប៉ារីសស្តីពីកម្ពុជា ត្រូវបានកោះប្រជុំតាមការ អញ្ជើញរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង ក្នុងទិស ដៅឈានទៅដល់ដំណោះស្រាយរួមមួយ ដោយមានការធានាជាអន្តរជាតិ ដែលនឹងនាំសន្តិភាពមកអោយប្រទេសវិញ ដែលបានឆ្លងកាត់ជម្លោះប្រកបដោយ សោកនាដកម្ម និង ការបង្ហូរឈាមនេះ ។

សន្និសិទបានប្រព្រឹត្តទៅ ដោយមានសម័យប្រជុំពីរលើក លើកទី មួយ ពីថ្ងៃទី ៣០ ខែកក្កដា ដល់ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៨៩ ហើយលើកទី ពីរ ពិថ្ងៃទី ២១ ដល់ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ។

២ - សហប្រធាននៃសន្និសិទមានៈ

ឯកឧត្តម រ៉ូឡង់ឌុយម៉ាស រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង និង ឯកឧត្តម អាលិអាឡា តាស រដ្ឋមន្ត្រី ក្រសួងការបរទេសនៃ សាធារណរដ្ឋឥណ្ឌូណេស៊ី ។

៣ - រដ្ឋដែលបានចូលរួមក្នុងសន្និសិទ មានដូចតទៅៈ

អូស្ត្រាលី ប្រ៊ុយណេដារុស្សាឡាម កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក សាធារណរដ្ឋបារាំង សធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត ឡាវ ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន ចក្រភពអង់គ្លេស និង អៀរឡង់ខាងជើង សាធារណរដ្ឋសឹង្ហបូរី រាជាណាចក្រថៃ ឡង់ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត សាធារណរដ្ឋសង្គមនិយមវៀតណាម ។

បន្ថែមពីលើនេះ ចលនាមិនចូលបក្សសម្ព័ន្ធ ត្រូវបានដំណាងដោយរដ្ឋ ដែលធ្វើជាប្រធានចលនានោះ ចំ ពេលដែលសន្និសិទ ប្រជុំមួយលើកៗនោះគឺ ហ្ស៊ីមបាបវេ នៅសម័យប្រជុំលើកទី ១ និង យូហ្គោស្លាវី នៅសម័យ ប្រជុំលើកទី ២ ។

៤ - ក្នុងឱកាសសម័យប្រជុំលើកទី ១ នៃសន្និសិទ ប្រទេសកម្ពុជាត្រូវបានតំណាង ដោយភាគីកម្ពុជាទាំង ៤ ។ ក្នុងឱកាស សម័យប្រជុំលើកទី ២ នៃសន្និសិទ ប្រទេសកម្ពុជាត្រូវបានតំណាង ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក្រោមអធិបតីភាព នៃប្រធាន របស់ខ្លួន គឺសម្តេច នរោត្តម សីហនុ ។

៥ - អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ឯកឧត្តម ហាវីយ៉េរ ប៉េរ៉េសដេគូអេយ៉ារ និង តំណាងពិសេសរបស់លោកគឺ លោករ៉ាហ្វីឌីនហ៍ម៉េដ ក៏បានចូលរួមក្នុងសន្និសិទនោះដែរ ។

៦ - សន្និសិទបានរៀបចំការងារ របស់ខ្លួនដោយបង្កើតនូវ គណៈកម្មការការងារចំនួន ៣ ដេលអ្នកចូលរួមទាំងអស់ មាន តំណាងរបស់ខ្លួន នៅក្នុងគណៈកម្មការទាំងនោះ ហើយដែលបានប្រជុំគ្នាក្នុងរយៈពេលនៃសម័យប្រជុំលើកទី ១ របស់សន្និសិទ ។ គណៈកម្មការទី ១ បានពិភាក្សាលើបញ្ហាយោធា គណៈកម្មការទី ២ បានពិភាក្សាលើការធានាជា អន្តរជាតិ គណៈកម្មការទី ៣ បានពិភាក្សាលើបញ្ហាមាតុភូមិនិវត្តន៍ នៃជនភៀសខ្លួន និង ជនផ្លាស់ប្តូទីកន្លែង និង ការ កសាងប្រទេសកម្ពុជាឡើងវិញ ។

បណ្តាប្រធាន និង អ្នករាយការណ៍ របស់គណៈកម្មការនិមួយៗ មានៈ

**ចំពោះគណៈកម្មការទី មួយ:**

*សហប្រធាន* : លោក ស.រ. ហ្កាវ៉េខាន់ (ឥណ្ឌា)
: លោក អាឡង់ ស៊ូលីវ៉ាន់ (កាណាដា)
*អ្នករាយការណ៍* : លោកស្រី វិតូយ៉ា ស៊ីសង់តេ បាតាក្លង់ (ហ្វីលីពីន)

**ចំពោះគណៈកម្មការទី ពីរ:**

*សហប្រធាន* : លោក ស៊ូលីវង្ស ប្រាស៊ីធីដេជ (ឡាវ)
: លោក ហ្សាណៃហ៍ អាប៊ីឌីន អ៊ីប្រាហ៊ីម (ម៉ាឡេស៊ី)
អ្នករាយការណ៍ : លោក អ៊ែរវ៉េ ដឺហ្សង់ដឺឡាបាទី (បារាំង)

**ចំពោះគណៈកម្មការទី បី:**

*សហប្រធាន* : លោក យូគីយ៉ូ អ៊ីម៉ាហ្កាវ៉ា (ជប៉ុន)
: លោក រ៉ូប៊ែរត៍ ម៉េរីល្លេស (អូស្ត្រាលី)
*អ្នករាយការណ៍* : វរៈសេនីយ៍ឯក រ៉ូណាជុក ស្វាសឌីគាត (ថៃឡង់)

សន្និសិទក៏បានបង្កើតផងដែរ នូវគណៈកម្មាធិការចំពោះកិច្ច (ADHOC) ដែលមានតំណាងរបស់ភាគីកម្ពុជា ទាំង បួនជាសមាជិក និង ដឹកនាំដោយតំណាង របស់អង្គការសហប្រធានទាំងពីរនៃសន្និសិទ ។ ភារកិច្ចនៃគណៈកម្មាធិការនេះ គឺទទួលបន្ទុកបញ្ហាដែលទាក់ទងដល់ដារ បង្រួបបង្រួមជាតិរវាង បណ្តាភាគីកម្ពុជា ។ គណៈកម្មាធិការចំពោះកិច្ចនេះ បាន ធ្វើការប្រជុំជាច្រើនលើកនៅក្នុងរយៈពេលនៃសម័យប្រជុំ លើកទី ១ របស់សន្និសិទ ។

គណៈកម្មាធិការសម្របសម្រួលនៃសន្និសិទ ដឹកនាំដោយតំណាងរបស់សហប្រធាន ទាំងពីត្រូវបានបង្កើតឡើង ហើយភារកិច្ចទទួលខុសត្រូវ លើការសម្របសម្រួលជាទូទៅ ចំពោះការងាររបស់គណៈកម្មការទាំង ៤ ផ្សេងទៀត ត្រូវបាន

ប្រគល់អោយគណៈកម្មាធិការនេះ ។

គណៈកម្មាធិការសម្របសម្រួល បានធ្វើការប្រជុំនារាល់ពេលសម័យប្រជុំទី ១ ទី ២ របស់សន្និសិទ ។ ការប្រជុំក្រៅផ្លូវការមួយរបស់គណៈកម្មាធិការសម្របសម្រួល ក៏បានប្រព្រឹត្តទៅនៅទីក្រុង ញូវយ៉ក កាលពីថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩១ កន្លងទៅនេះផងដែរ ។

៧ - នៅទីបញ្ចប់នៃសម័យប្រជុំលើកទី ១ សន្និសិទបានជឿនលឿនទៅមុខ ក្នុងការរៀបចំនូវចំណុចផ្សេងៗ ជាច្រើននិងចាំបាច់ ដើម្បីឈានទៅដល់ដំណោះស្រាយរួមមួយ នៃជំលោះកម្ពុជា ។ ក៏ប៉ុន្តែសន្និសិទបានកត់សម្គាល់ថា នៅពុំទាន់មានលទ្ធភាព ឈានទៅដល់ដំណោះស្រាយរួម នៅឡើយទេ ។

ហេតុដូច្នេះមានការសម្រេចថា ត្រូវផ្អាកសន្និសិទនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៨៩ សិន ។ ជាមួយគ្នានោះ សន្និសិទបានអំពាវនាវ ដល់ភាគីដែប់ទាក់ទិនទាំងអស់ អោយបង្កើនការខិតខំ ដើម្បីឈានទៅដល់ដំណោះស្រាយរួម និង បានស្នើដល់សហប្រធានអោយចួយឧបត្ថម្ភជ្រោមជ្រែងសម្រួល ដល់ការខិតខំទាំងនោះ ។

៨ - បន្ទាប់ពីការផ្អាកសម័យប្រជុំលើកទី ១ នៃសន្និសិទមក សហប្រធាន និង អគ្គលេខាធិការអង្គការសហប្រជាជាតិ បានធ្វើការពិគ្រោះយ៉ាងទូលំទូលាយ ជាពិសេសជាមួយសមាជិកអចិន្ត្រៃយ៍ទាំង ៥ របស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ជាមួយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៃកម្ពុជា និងជាមួយអ្នកចូលរួមដទៃទៀត នៃសន្និសិទប៉ារីស ។

កម្មវត្ថុនៃការពិគ្រោះទាំងនោះ គឺការរៀបចំកិច្ចព្រមព្រៀងមួយ ស្តីពីទិដ្ឋភាពទាំងអស់ នៃដំណោះស្រាយ ការធានានូវ ទំនាក់តំនងនៃគនិតផ្តួចផ្តើមទាំងអស់ ដែលត្រូវបានអនុមតិក្នុងគោលបំណងនោះ និង ការបង្កើនលទ្ធភាពក្នុងការបញ្ចប់ការបង្ហូរឈាមនៅកម្ពុជា អោយបានឆាប់រហ័សជាទីបំផុត ។ ការប្រឹងប្រែងរបស់សហប្រធាន និង អគ្គលេខាធិការ បានអនុញ្ញាត អោយកោះប្រជុំជាថ្មី នូវសន្និសិទ ទីក្រុងប៉ារីសស្តីពីកម្ពុជា ។

៩ - នៅក្នុងដំណាក់កាលបើកសម័យប្រជុំបញ្ចប់ នៃសន្និសិទប៉ារីសថ្ងៃ ២៣ តុលា ១៩៩១ ឯកឧត្តម ហ្វ្រង់ស្វាមីតេរ៉ង់ ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង សម្តេច នរោត្តម សីហនុ ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា និង ឯកឧត្តម ហាវីយ៉េប៉េរ៉េសដេគូអេយ៉ារ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានអានសុន្ទរកថា ចំពោះអង្គសន្និសិទ ។

១០ - នៅក្នុងសម័យប្រជុំលើកទី ២ សន្និសិទបានអនុមតិនូវ ឯកសារដូចខាងក្រោមៈ

ក - កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយរួមមួយ នៃជម្លោះកម្ពុជា ដោយមានភ្ជាប់នូវឧបសម្ព័ន្ធ ស្តីពិភារកិច្ចរបស់អាជ្ញាធរបណ្តោះអាសន្ន អ.ស.ប. នៅកម្ពុជា បញ្ហាយោធា ការបោះឆ្នោត មាតុភូមិនិវត្តន៍ នៃជនភៀសខ្លួនកម្ពុជា និង ជនផ្លាស់ប្តូរទីកន្លែង និង បណ្តាគោលការណ៍ សម្រាប់រដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា ។

ខ - កិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រិត

ភាព និង អេកភាពជាតិរបស់កម្ពុជា ។

គ - សេចក្ដីថ្លែងការណ៍ស្ដីពីការស្ដារ និង ការកសាងប្រទេសកម្ពុជាឡើងវិញ ។

ឯកសារទាំងនេះ ត្រូវបានរៀបរៀងឡើងលើមូលដ្ឋាននៃ "ឯកសារក្របខ័ណ្ឌដើម្បីដំណោះស្រាយ នយោបាយរួមនៃជម្លោះកម្ពុជា" ដែលត្រូវបានអនុមតិ ដោយសមាជិកអចិន្ត្រៃយ៍ទាំង ៥ នៃក្រុមប្រឹក្សាសន្តិសុខ សហប្រជាជាតិកាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៩០ និង ឯកសារការងារដែលត្រូវបានរៀបចំឡើង នាសម័យប្រជុំលើកទី ១ របស់សន្និសិទ ។ ឯកសារទាំងនេះ គ្រោងនូវដំណើរការបន្តបន្ទាប់មួយ នៃការបង្រួបបង្រួមជាតិ ព្រមទាំងតួនាទីមួយដ៏ទូលំទូលាយ របស់អង្គការសហប្រជាជាតិ ដែលអនុញ្ញាតអោយប្រជាជនកម្ពុជា កំណត់យកអនាគតនយោបាយរបស់ខ្លួន តាមរយៈការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ រៀបចំ និង ដឹកនាំដោយអង្គការសហប្រជាជាតិ នៅក្នុងបរិយាកាស នយោបាយអព្យាក្រឹតមួយ និង ដោយមានការគោរពពេញទី ចំពោះអធិបតេយ្យភាពជាតិរបស់កម្ពុជា ។

១១ - ឯកសារទាំងនេះ ដែលរួមគ្នាមកគឺជាដំណោះស្រាយរួម ដែលជាគោលដៅរបស់សន្និសិទប៉ារីសនោះ ត្រូវបានបើកឡើង ដើម្បីអោយបណ្ដារដ្ឋចូលរួមសន្និសិទ ប៉ារីសចុះហត្ថលេខា ។ ចំពោះប្រទេសកម្ពុជា ឯកសារទាំងនេះនឹងត្រូវបានចុះហត្ថលេខា ដោយសមាជិកទាំង ១២ នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ដែលជាអង្គការស្របច្បាប់ និង ជាប្រភពនៃអំណាចតែមួយគត់ តំណាងអោយ អធិបតេយ្យភាព ឯករាជ្យ និង ឯកភាពជាតិរបស់កម្ពុជា ។

១២ - បណ្ដារដ្ឋចូលរួមក្នុងសន្និសិទ ស្នើសុំអោយសហប្រធាននៃសន្និសិទបញ្ជូននូវ ច្បាប់ត្រឹមត្រូវមួយច្បាប់ នៃឯកសារស្ដីពីដំណោះស្រាយនយោបាយរួមនេះ ជូនលោកអគ្គលេខាធិការ អ.ស.ប. ។ បណ្ដារដ្ឋចូលរួមសន្និសិទ ស្នើដល់លោកអគ្គលេខាធិការ អោយប្រកាន់យកនូវបទកំណត់សមស្រប អោយដំណោះស្រាយរួមនេះ ត្រូវបានក្រុមប្រឹក្សាសន្តិសុខ សហប្រជាជាតិពិនិត្យយ៉ាងឆាប់បំផុត ។ បណ្ដារដ្ឋទាំងនេះសន្យាថា នឹងសហការណ៍យ៉ាងពេញទំហឹង ដើម្បីអោយដំណោះស្រាយរួមនេះ ត្រូវបានសម្រេច ហើយនឹងជួយនៅក្នុងការអនុវត្តដំណោះស្រាយនេះ ។

ជាពិសេស ដោយមើលឃើញនូវប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មនៃប្រទេសកម្ពុជា បណ្ដារដ្ឋចូលរួមក្នុងសន្និសិទ បានសន្យាជំរុញ និង លើកទឹកចិត្តអោយមានការគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន នៅក្នុងប្រទេសកម្ពុជា ដូចមានចែងនៅក្នុងបណ្ដាកិច្ចព្រមព្រៀងអន្តរជាតិ ដែលទាក់ទងដល់បញ្ហានេះ ហើយដែលបណ្ដារដ្ឋនោះ ជាភាគីចូលរួមផងដែរ ។

១៣ - បណ្ដារដ្ឋចូលរួមក្នុងសន្និសិទ ស្នើអោយគណៈកម្មាធិការ កាកបាតក្រហមអន្តរជាតិ ជួយសម្រួលការដោះលែងឈ្លើយសឹក និង អ្នកជាប់ឃុំឃាំងស៊ីវិល ស្របតាមគោលការណ៍របស់ខ្លួន ។ បណ្ដារដ្ឋទាំងនេះ ត្រៀមនឹងជួយដល់ គណៈកម្មាធិការ កាកបាតក្រហមអន្តរជាតិនៅក្នុងភារកិច្ចនេះ ។

១៤ - បណ្ដារដ្ឋចូលរួមក្នុងសន្និសិទ សូមអញ្ជើញដល់បណ្ដារដ្ឋផ្សេងទៀត អោយចូលរួមក្នុងកិច្ចព្រមព្រៀង ស្ដីពីដំណោះស្រាយនយោបាយរួមមួយ នៃជម្លោះកម្ពុជា និង ក្នុងកិច្ចព្រមព្រៀងស្ដីពិអធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិន

មិនអាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់កម្ពុជា ។

១៥ - ដោយពិនិត្យឃើញនូវសេចក្តីត្រូវការ អោយមានការខិតខំប្រឹងប្រែង ជាអន្តរជាតិដោយស៊ីសង្វាក់គ្នា ដើម្បីជួយដល់ការស្តារ និង ការកសាងប្រទេសកម្ពុជាឡើងវិញ បណ្តារដ្ឋចូលរួមសន្និសិទ អំពាវនាវដោយទទូច ដល់សហគមន៍អន្តរជាតិ អោយផ្តល់នូវការគាំទ្រជាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយសប្បុរស ស្របតាមវិធានការ ដែលត្រូវបានលើកឡើងនៅក្នុង សេចក្តីថ្លែងការណ៍ ស្តីពិការស្តារ និង ការកសាងប្រទេសកម្ពុជាឡើងវិញ ។

ដើម្បីជាសំអាង បណ្តាតំណាងបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងបញ្ចប់នេះ ។

ធ្វើនៅទីក្រុងប៉ារីស ថ្ងៃទី ម្ភៃបី (២៣) ខែតុលា (១០) ឆ្នាំ មួយពាន់ប្រាំបួនរយ កៅសិបមួយ (១៩៩១) ជាពីរច្បាប់ ជាភាសាចិន អង់គ្លេស បារាំង ខ្មែរ និង រុស្ស៊ី ដោយច្បាប់ជាភាសានិមួយៗ មានតម្លៃដូចគ្នា ។ ច្បាប់ដើមនៃកិច្ចព្រមព្រៀងបញ្ចប់នេះ នឹងត្រូវតម្កល់ទុកនៅនឹង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និង សាធារណរដ្ឋឥណ្ឌូណេស៊ី ។

**- ចប់ -**